ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ

THE MESSENGER

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១១ | សម្រាប់ខែ ឧសភា ឆ្នាំ ២០១៩ | តម្លៃលក់ ១០០០រៀល | លេខ #១២០

## សាធារណជនបារម្ភអំពីការរីករាលដាល អូទីហ្សឹមនៅកម្ពុជា

> ទំព័រ ១០-១១



# សាវ័កព្រះយេស៊ូត្រូវប្រកាសដំណឹងល្អ តាមរយៈសកម្មភាពមេត្តាករុណា

*ដោយ៖ លី សុវណ្ណា*

ព្រះជាម្ចាស់បានបង្កើតមនុស្សជារូបតំណាងរបស់ព្រះអង្គនៅក្នុងលោកយើងនេះ។ ព្រះអង្គក៏ប្រទានប្រាជ្ញាដល់មនុស្សផងដែរ ដើម្បីឲ្យគេរស់នៅ គ្រប់គ្រងផែនដីនេះ។ ព្រះជាម្ចាស់ស្រលាញ់មនុស្សជានិច្ចរហូតចាត់ព្រះបុត្រាឲ្យយាងមកកើតជាមនុស្សដូចយើង គឺព្រះយេស៊ូគ្រីស្តជាអម្ចាស់។ ព្រះយេស៊ូរងទុក្ខលំបាក រហូតសោយទិវង្គត នៅលើឈើឆ្កាងយ៉ាងអាម៉ាស់ ដើម្បីនាំមនុស្សឲ្យស្គាល់ធម៌មេត្តារបស់ព្រះជាម្ចាស់ជាព្រះបិតា។ ព្រះបិតាក៏ប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញ។

ព្រះយេស៊ូចាត់យើងជាសាវ័ករបស់ព្រះអង្គឲ្យបន្តមុខងារដែលព្រះអង្គបានបំពេញ គឺនាំមនុស្សឲ្យស្គាល់ពន្លឺរបស់ព្រះជាម្ចាស់។ តើយើងគ្រីស្តបរិស័ទត្រូវប្រព្រឹត្តយ៉ាងដូចម្តេចដើម្បីនាំពន្លឺរបស់ព្រះជាម្ចាស់ ដល់មនុស្សឯទៀតនោះ?

ជាច្រើនលើកច្រើនសារ បងប្អូនគ្រីស្តបរិស័ទ បានទទួលស្តាប់ព្រះបន្ទូល ដែលនិយាយអំពីសេចក្តីស្រលាញ់ដ៏លើសលប់របស់ព្រះជាម្ចាស់។ និងបានទទួលយកនូវវិន័យដ៏សំខាន់ដែលព្រះយេស៊ូបានប្រទានមកឲ្យយើងដែរ គឺ " អ្នករាល់គ្នាស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ"។ នេះជាអ្វីដែលគ្រីស្តបរិស័ទត្រូវតែអនុវត្តជានិច្ច។ តើបងប្អូនមានពិសោធន៍ទទួលបានសេចក្តីស្រលាញ់ពីសាវ័ក (ព្រះសហគមន៍) របស់ព្រះយេស៊ូឬទេ? តើបងប្អូន មានពិសោធន៍អនុវត្តវិន័យនេះបែបណាដែរ?

ព្រះសហគមន៍កាតូលិកត្រូវតែប្រណិប័តន៍ជានិច្ច ដោយទទួលស្វាគមន៍បងប្អូន គ្រប់ប្រភេទ អ្នកក្រីក្រ ស្ត្រីមេម៉ាយ ចាស់ជរា ជនមានពិការភាព លើកទឹកចិត្តជនមានទុក្ខព្រួយជាដើម។ ជាងនេះ ព្រះសហគមន៍ក៏បានយកចិត្តទុកដាក់ដល់អ្នកដែលស្លាប់ទៅហើយដែរ ជាពិសេសអស់អ្នកដែលគ្មានគេរំលឹកនឹកដល់។

ទោះជាយ៉ាងនេះ ព្រះសហគមន៍ក៏នៅតែត្រូវការកម្លាំងបន្ថែមពីសំណាក់គ្រីស្តបរិស័ទទាំងអស់ មានយុវជន និងមនុស្សពេញវ័យ ព្រមទាំងចាស់ទុំទាំងឡាយ។ នៅក្នុងព្រះសហគមន៍នៅកម្ពុជា មានបងប្អូនមួយចំនួនបានចេះសកម្មភាព និងអនុវត្តជាប្រចាំទៅហើយ។ តែនៅមួយចំនួនត្រូវការពេលវេលាបន្តទៀត។ ជាច្រើនលើកច្រើនសារ លោកអភិបាលព្រះសហគមន៍កាតូលិក តែងជំរុញគ្រីស្តបរិស័ទឲ្យចេញសកម្មភាពនៃធម្មមេត្តាករុណាជានិច្ច ដើម្បីឲ្យព្រះបន្ទូល និងការប្រកាសដំណឹងល្អរបស់យើងចេញជារូបរាងពិតៗ។



*កខគឃង។ រូបភាព៖ លីហៀង*

ព្រះសហគមន៍នៅកម្ពុជាបានស្លាប់មួយរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៩០។ គ្រីស្តបរិស័ទមិនអាចជួបជុំគ្នា មិនអាចមានសកម្មភាពលើកតម្កើងព្រះជាម្ចាស់ក៏គ្មានសកម្មភាពនៃមេត្តាករុណាក្នុងនាមព្រះអម្ចាស់ដែរ។ ក្រោយរស់ឡើងវិញក្នុងឆ្នាំ១៩៩០ ព្រះសហគមន៍មានសកម្មភាពឡើងវិញក្នុងការជួបជុំ និងសម្តែងធម៌មេត្តាករុណា។ មានបងប្អូនជាច្រើនបានទទួលស្គាល់ព្រះនាមព្រះយេស៊ូ និងដើរតាមព្រះអង្គតាមរយៈសកម្មភាពរបស់គ្រីស្តបរិស័ទ។ មានព្រះសហគមន៍ថ្មីជាច្រើនក៏បានកកើតឡើងផងដែរ។

នៅក្នុងសង្គមយើង ទោះបីជារីកចម្រើនយ៉ាងឆាប់រហ័ស មិនខ្វះទេជនដែលត្រូវគេបៀតបៀនរងនូវភាពអយុត្តិធម៌ កុមារដែលម្តាយបោះបង់ចោល ស្ត្រីមេម៉ាយទីទាល់ក្រ ចាស់ជរាគ្មានទីពឹង អ្នកជំងឺគ្មានថ្នាំព្យាបាល អ្នកថែរក្សាជនមានពិការភាព អ្នកអស់សង្ឃឹម ទន់ខ្សោយខាងផ្លូវវិញ្ញាណ ជនខ្សោយសតិបញ្ញា ជនដែលគេបោះបង់ចោល និងមិននឹកនាជាដើម។

តើយើងត្រូវចូលរួមក្នុងសកម្មភាពយកចិត្តទុកដាក់ជាមួយបងប្អូនទាំងនោះរបៀបណា?

នៅថ្ងៃបុណ្យនឹករលឹកដល់វិញ្ញាណក្ខន្ធបងប្អូន ដែលបានចែកឋានទៅក្នុងសម័យប៉ុលពត លោកអភិបាលអូលីវីយេ បានលើកទឹកចិត្តយុវជន និងគ្រីស្តបរិស័ទទាំងឲ្យយកចិត្តទុកដាក់ចូលរួមយ៉ាងសកម្មក្នុងកិច្ចការរបស់ព្រះសហគមន៍ ក្នុងការប្រកាសដំណឹងល្អ អំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដោយបើកចិត្តគំនិតចំហរទទួលស្វាគមន៍បងប្អូនជានិច្ច និងបើកចិត្តគំនិតដើម្បីចែករំលែកជានិច្ច ជាសៀងដាច់ខាតពីអំពើពុករលួយ ភាពលោភលន់ និងអាត្មានិយម ដោយយកគំរូតាមមរណសាក្សីនៃយើង៕

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក



# ពលការិនី៖ ទីណាក៏ដូចទីណា ប្រាក់ខែដូចតែគ្នា តែបរិយាកាសការងាររាងខុសគ្នា

*ដោយ៖ អរិយបុត្រ*

ពលការិនីរោងចក្រមួយចំនួនដែលកំពុងតែអង្គុយហូបបាយថ្ងៃត្រង់នៅម្លប់ឈើនៃរោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុបានអះអាងថា ទីណាក៏ដូចជាទីណាដែរ គឺលក្ខខណ្ឌការងារ និងប្រាក់បៀវត្សរ៍គឺត្រូវបានកំណត់ដូចគ្នាទាំងអស់។

កញ្ញា លន់ ស្រីមុំ ជាកម្មការិនីរោងចក្រមួយរូបនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ បានអះអាងថា កញ្ញាបានមកបំពេញការងារនៅរោងចក្រកាត់ដេរនាតំបន់សេដ្ឋកិច្ចពិសេសនេះប្រហែលជា៣ឆ្នាំមកហើយ ក្រោយពេលដែលបំពេញការងារនៅរាជធានីភ្នំពេញបាន៤ទៅ ៥ឆ្នាំ។

កញ្ញាបន្តថា តាមបទពិសោធរបស់កញ្ញានៅក្នុងនាមជាកម្មការិនីរោងចក្រ គឺទីណាក៏ដូចជាទីណាដែរ គ្មានអ្វីខុសគ្នាទេ ទាំងប្រាក់បៀវត្សរ៍ និងលក្ខខណ្ឌការងារគឺដូចគ្នាទាំងអស់។

នារីកម្មការិនីរោងចក្រដែលមានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំងមួយរូបនេះ បានបញ្ជាក់ថា៖ «ខ្ញុំធ្លាប់ធ្វើការនៅភ្នំពេញ និងនៅទីនេះ គឺអត់មានអ្វីខុសគ្នាទេ តែទីនេះរាងមានបរិយាកាសល្អ និងកន្លែងរស់នៅស្អាតបន្តិច»។

កម្មការនីមួយរូបទៀតដែលកំពុងតែសម្រាកទទួលទានអាហារថ្ងៃត្រង់ដែរ ក៏បានចែករំលែក និងជួយប្រៀបធៀបរវាងបណ្តារោងចក្រនៅរាជធានីភ្នំពេញ និងនៅតំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះសីហនុថា ភាពខុសគ្នា គឺមានតែរឿងបរិស្ថានបរិយាកាសការងារ និងអត់ស្ទះចរាចរណ៍ទេ។

កញ្ញា លឹម មិនា ដែលជាកម្មការិនីនៅរោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះដែរនោះ បានលើកឡើងថា ប្រាក់បៀវត្សរ៍អីគឺដូចគ្នាទាំងអស់ ហើយទីនេះ ដូចជារបស់របរអីថ្លៃជាងនៅភ្នំពេញផង ប៉ុន្តែគ្រាន់តែថា វាដូចជាស្រួលចិត្តស្រួលខ្លួន ដោយសារតែទីនេះមានខ្យល់ មានអាកាសល្អ ហើយពេលចេញពេលចូលធ្វើការអី មិនស្ទះទេ។

កញ្ញាបានរៀបរាប់ថា ក្រៅពីនេះដូចជាដូចគ្នាទាំងអស់ គឺកម្មករនិងកម្មការិនីម្នាក់ៗត្រូវគេងផ្ទះជួលខ្លួនឯង ចេញទឹកចេញភ្លើងខ្លួនឯង ហូបចុកអាហារអីដូចតែគ្នា ហើយម៉ោងពេលធ្វើការក៏ដូចគ្នា ដោយមួយថ្ងៃត្រូវធ្វើការ១០ម៉ោង ពីថ្ងៃច័ន្ទដល់សៅរ៍ដូចគ្នា ដោយនៅក្នុងនោះ ធ្វើការម៉ោងសុទ្ធ៨ ម៉ោង និងថែមម៉ោងគឺ ២ម៉ោង ដោយឡែកប្រាក់ឈ្នួលអីគឺដូចគ្នា។



*កម្មករកម្មការិនីរោងចក្រកាត់ដេរខេត្តព្រះសីហនុជួបសំណេះសំណាលជាមួយនឹងសម្តេចតេជោ ហ៊ុន សែន។ រូបភាព៖ ហ្វេសប៊ុក*

> **“ប្រាក់បៀវត្សរ៍អីគឺដូចគ្នាទាំងអស់ ហើយទីនេះ ដូចជារបស់របរអីថ្លៃជាងនៅ ភ្នំពេញផង ប៉ុន្តែគ្រាន់តែថា វាដូចជាស្រួលចិត្តស្រួលខ្លួន ដោយសារតែទីនេះមានខ្យល់ មានអាកាសល្អ ហើយ ពេលចេញពេលចូលធ្វើការអី មិនស្ទះទេ។”**

លោក លាង បញ្ញា ជាកម្មករនៅរោងកច្រផលិតវត្ថុអនុស្សាវរីយមួយរូបបានអះអាងថា ជីវិតជាកម្មករគឺទីណាក៏ដូចជាទីណាដែរ ពីព្រោះគេកំណត់តាំងពីលើមកអស់ហើយ យើងដឹងតែដល់ម៉ោងគឺដឹងតែពីធ្វើការ ប៉ុន្តែទីនេះ (ខេត្តព្រះសីហនុ) ទោះបីជារបស់ហូបចុកអីរាងថ្លៃ តែដូចជាសល់លុយច្រើនដែរ ។ លោកបានបន្តថា មូលហេតុដែលសល់លុយ គឺដោយសារតែទីនេះមិនសូវមានកន្លែងដើរលេងអីច្រើន។ កម្មករដឹងតែពីចេញពីឬធ្វើការទៅផ្ទះសម្រាក ហើយបើដើរលេងមានតែទៅឆ្នេរ ឬជួបជុំគ្នាបន្តិចបន្តួចនៅមុខរោងចក្រ អត់មានទៅណាទៅណីដូចជាការឬធ្វើការនៅភ្នំពេញ។

លោកបានបញ្ជាក់ថា៖ «នៅទីនេះតែចេញពីធ្វើការ៥ និង ៣០នាទី ទៅ៦អី គឺដឹងតែទៅផ្ទះជួលសម្រាកហើយ អត់មានទៅក្លឹបទៅអីដូចនៅភ្នំពេញ ដាច់ៗយប់ទេ»។

តាមការកំណត់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ថា សម្រាប់ឆ្នាំ២០១៩ ប្រាក់បៀវត្សរ៍ដែលកម្មករ និងកម្មការិនីរោងចក្រទទួលបាន គឺ ១៧៧ដុល្លារ ហើយនិងថវិកាជាតិបន្ថែម ៥ដុល្លារទៀត។ ដូច្នេះប្រាក់ឈ្នួល កម្មករសម្រាប់ឆ្នាំ២០១៩ គឺ១៨២ដុល្លារ និងត្រូវបានបញ្ជាឲ្យបើកជា ២ដងក្នុងមួយខែខណៈ ដែលប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៨នេះគឺ ១៧០ដុល្លារក្នុងមួយខែ។ ប៉ុន្តែជាទូទៅកម្មករ និងកម្មការិនីនៅទទួលបានប្រាក់បន្ថែមម៉ោង និងថ្លៃជិកជញ្ជូនបន្ថែមក្រៅថែមទៀតខ្លះផងដែរ។

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ នេះមានទំហំជាងមួយពាន់ហិកតានោះ ជាតំបន់សេដ្ឋកិច្ចសហប្រតិបត្តិការអន្តរជាតិក្រុមទី ១ របស់ប្រទេសចិន ដែលរួមគ្នាបណ្តាក់ទុនវិនិយោគ និងរៀបចំបង្កើតដោយក្រុមហ៊ុន ហុងទូវ ខេត្តជាំងស៊ូ ប្រទេសចិន និងសហគ្រាសមួយចំនួនទៀត។ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុជាគម្រោងមួយតាមបណ្តោយ «ខ្សែក្រវាត់មួយ និងផ្លូវមួយ» របស់ចិន។ គិតមកដល់ពេលនេះ សហគ្រាសចំនួនជាង ១៣០ មកពីប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង អឺរ៉ុប និងអាមេរិកជាដើម កំពុងតែបោះទុននៅក្នុងតំបន់នេះ និងផ្តល់ការងារដល់ប្រជាជនខ្មែរជាង ២,១ ម៉ឺននាក់៕



*កម្មការិនីកាត់ដេរខេត្តព្រះសីហនុថតរូបអនុស្សាវរីយជាមួយសម្តេចតេជោ ហ៊ុន សែន ក្នុងឱកាសចុះសួរសុខទុក្ខនាពេលកន្លងមក។ រូបភាព៖ ក្រសួងការងារ*



*កម្មករកម្មការនីបម្រើការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ។ រូបភាព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*



សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោក ស៊ី ជីពីង ប្រធានាធិបតីចិនក្នុងវេទិកា «ខ្សែក្រវ៉ាត់ និងផ្លូវ»លើកទី២ នៅសាធារណរដ្ឋប្រជាមានិតចិន ។ រូបភាព៖ ហ្វេសប៊ុកសម្តេចតេជោ

# ដូចជាមិនខាតបង់អ្វីទេ ដែលកម្ពុជាជាផ្នែកមួយនៃគំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ»របស់ចិន!

**គំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ» គឺជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍមួយ ដែលអនុម័តដោយរដ្ឋាភិបាលចិន ក្រោមរដ្ឋបាលរបស់លោកប្រធានាធិបតី ស៊ី ជីនភីង ដោយមកដល់ពេលបច្ចុប្បន្ននេះ វាមាន គម្រោងបណ្តាក់ទុន និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធជាមួយនឹងប្រទេស រហូតដល់ទៅ ១៥២ ប្រទេស នៅក្នុងប្រទេសទាំងអស់ ជាង ១៩០ប្រទេស នៅក្នុង អឺរ៉ុប អាស៊ី មជ្ឈឹមបូព៌ាអាមេរិកឡាទិន និងអាហ្វ្រិក ដូច្នេះវាមិនមែនជាការខាតបង់ទេ សម្រាប់កម្ពុជានៅក្នុងការចូលរួម និងគាំទ្រនូវទស្សនវិស័យនេះ។**

*ដោយ៖ អរិយបុត្រ*

ដោយឈរនៅលើទស្សនវិស័យនៃការអនុវត្តឲ្យបានជោគជ័យនៃគម្រោងនេះ ចិនប៉ុនប៉ង និងជំរុញអនុវត្ត គំនិតផ្តួចផ្តើមនេះ ឲ្យទៅដល់គោលដៅ នៅក្នុងរង្វង់ឆ្នាំ ២០៤៩ ពោលគឺនៅក្នុងខួបទី ១០០ឆ្នាំនៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ហើយដោយឡែកវាក៏ស្របគ្នានឹងទស្សនវិស័យរបស់ប្រមុខ កម្ពុជានៅក្នុងការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសមួយដែលមានចំណូលខ្ពស់នៅក្នុងឆ្នាំ ២០៥០ ផងដែរ។

តាមផែនទីបង្ហាញផ្លូវនៅក្នុងការអនុវត្តនូវគំនិតផ្តួចផ្តើមដ៏មហាសាលនេះ ចិន កំពុងតែព្យាយាមកសាងនូវរចនាសម្ពន្ធភូមិសាស្ត្រនូវច្រករបៀងនិងផ្លូវសូត្រសមុទ្រជាច្រើនគម្រោងនៅក្នុងរង្វង់ប្រទេស ប្រមាណជា ៦០ប្រទេស នៅអាស៊ី និងអឺរ៉ុបជាបណ្តើរៗ ហើយក៏គ្រោងនឹងបន្តទៅទ្វីបអូសេអានី និងអាហ្វ្រិកខាងកើតថែមទៀតដោយគម្រោងនេះ ត្រូវបានគេរំពឹងថា នឹងមានទឹកប្រាក់ដ៏មហាសាល គឺពីនៅក្នុងរង្វង់ពី ៤ ទៅ ៨ ទ្រីលាន ដុល្លារ។

ក្រោយពីគំនិតផ្តួចផ្តើមនេះ ត្រូវបានដាក់ចេញ កាលពីឆ្នាំ វាត្រូវបានគេដឹងថា កំពុងតែប្រឈមមុខ នឹងត្រូវប្រទាំងប្រទើសជាមួយនឹងទស្សនវិស័យពីររបស់អាមេរិក គឺភាពជាដៃគូអន្តរប៉ាស៊ីហ្វិក និងភាពជាដៃគូនៃការបណ្តាក់ទុន និងពាណិជ្ជកម្មអន្តរអាត្លង់ទិចរបស់អាមេរិក ប៉ុន្តែហាក់ដូចជាថមថយ នាពេលបច្ចុប្បន្នក្រោមរដ្ឋបាលលោកប្រធានាធិបតីអាមេរិក ដូណាល់ត្រាំ ប៉ុន្តែកំពុងតែរងនូវឥទ្ធិពលនៃការប្រកួតប្រជែងនឹងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក របស់អាមេរិក និងជប៉ុន។

នៅក្នុងនាមជាប្រទេសដែលមិនចូលបក្សសម្ព័ន្ធ ជាសមាជិកនៃប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលគេស្គាល់ថា អាស៊ាន កម្ពុជាកំពុងតែស្ថិតនៅលើគន្លងនៃការប្រទាញប្រទង់មួយនៃយុទ្ធសាស្ត្ររបស់មហាអំណាច ទាំងបី នេះ ហើយក៏កំពុងតែព្យាយាមនៅក្នុងការសម្របសម្រួលដើម្បីផលប្រយោជន៍ សេដ្ឋកិច្ចទាំងអស់ដើម្បីសម្រេចបាននូវទស្សនវិស័យមួយផ្ទាល់ខ្លួន។

ដើម្បីរក្សានូវឥទ្ធិពលចិនដែលគេដឹងថា កំពុងតែក្លាយជាដៃគូនៃការដណ្តើមកិត្យានុភាពដ៏សម្បើម ជំនួសតួនាទីពិភពលោក នោះអាមេរិក តែងតែសង្កត់ធ្ងន់ និងជម្រុញមហាអំណាចនៅខាងលិច ជាពិសេស ប្រទេសនៅក្នុងសហគមន៍អឺរ៉ុប កុំឲ្យចូលរួមនូវគំនិតផ្តួចផ្តើមនេះ យ៉ាងខ្លាំងក្លា ប៉ុន្តែថ្មីៗនេះ យើងឃើញថាប្រទេសមួយចំនួនអឺរ៉ុបក៏កំពុងតែងាកផ ហើយក៏មានប្រទេសមួយចំនួន បានចូលរួម នូវគំនិតផ្តួចផ្តើមនេះរួចមកហើយដែរ។

ចាប់តាំងពីគំនិតផ្តួចផ្តើម «ផ្លូវមួយ និងខ្សែក្រវ៉ាត់មួយ» ត្រូវបានដាក់ចេញកាលពី អំឡុងខែកញ្ញា និងតុលា ឆ្នាំ ២០១៣ រួចមក ប្រទេសជាច្រើនបានទទួលគម្រោងវិនិយោគ និងកសាងហេដ្ឋារចនាសម្ពន្ធហើយនៅក្នុងនោះ កម្ពុជាក៏ទទួលបានផ្លូវការពីគម្រោងនេះជាច្រើនដែរមកដល់ពេលនេះ។

ដូចដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានលើកឡើង នាវេទិកាខ្សែក្រវ៉ាត់ និងផ្លូវលើកទីពីរនៅទីក្រុងប៉េកាំង កាលពីចុងខែ មេសាកន្លងទៅនេះ ជាលំអាន និងទស្សនវិជ្ជាដែលនឹងរួមគ្នា ពោលគឺប្រទេសខ្លាំងជួយប្រទេសខ្សោយ ប្រទេសមានជួយប្រទេសដែលនៅខ្វះខាត ក្នុងគោលដៅតែមួយ និងរួមគ្នាជួយគ្នាដើម្បីឱ្យយើងមានវាសនាអនាគតរុងរឿងដូចគ្នា។

នៅក្នុងយុគសម័យឌីជីថលពិភពលោកទាំងមូល លែងបែងចែកជាទ្វីបទៀតហើយយើងទាំងអស់គ្នារស់នៅយ៉ាងកៀកបង្កើយដោយរួមសុខរួមទុក្ខ ហើយគំនិតផ្តួចផ្តើមនេះគឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងវាសនារួមគ្នាប៉ុណ្ណោះ ដែលនឹងទ្រទ្រង់មនុស្សជាតិទាំងមូលអាចបន្តរួមរស់ជាមួយគ្នាដោយសុខដុមរមនា និងសន្តិភាព។

សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងនៅក្នុង





វេទិកានេះថា ក្នុងរយៈពេលជិត ៦ឆ្នាំនៃការអនុវត្តកន្លងមក។ គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវសម្រេចបានផ្លែផ្កាគួរឲ្យកត់សម្គាល់ជាច្រើន សម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងលើសកលលោក ទាំងការតភ្ជាប់គ្រប់ប្រព័ន្ធរូបវ័ន្ត និងអរូបវ័ន្ត ការបន្ស៊ី និងការសម្របសម្រួលគោលនយោបាយអភិវឌ្ឍន៍ ការវិនិយោគនៅក្នុងវិស័យហេដ្ឋារចនាសម្ពន្ធ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងការផ្លាស់ប្តូរវប្បធម៌ និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ដែលវឌ្ឍនភាពទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃលំហូរពាណិជ្ជកម្ម លំហូរមូលធន លំហូរទេសចរណ៍ ការផ្លាស់ប្តូរវប្បធម៌ និង ការផ្ទេរបច្ចេកវិទ្យាជាដើម។ ប្រការនេះពិតជាបានរួមចំណែកដល់ការលើកស្ទួយសុខមាលភាព និងការអភិវឌ្ឍតំបន់របស់យើងទាំងក្នុងវិស័យសន្តិសុខ សេដ្ឋកិច្ច និងសង្គម លើសពីនេះទៀត ចំនួនប្រទេសចូលរួមក្នុងវេទិកាខ្សែក្រវ៉ាត់ និងផ្លូវលើកទី២ មានការកើនឡើងគួរឲ្យកត់សម្គាល់ ដែលនេះគឺជាសញ្ញា នៃការរីកដុះដាល និងភាពកាន់តែរឹងមាំជាលំដាប់នូវការផ្តល់សេចក្តីគាំទ្រ និងការជឿទុកចិត្តលើគំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ»សម្រាប់ការលើកកម្ពស់សន្តិភាព ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងពង្រឹងវិបុលភាពតំបន់ និងនៅលើសាកលលោក។

តាមប្រសាសន៍សម្តេចតេជោ នាពេលនោះ៖ ការដាក់ចេញ និងអនុវត្តន៍នូវក្របខណ្ឌគំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ» ជាសក្ខីកម្មមួយយ៉ាងប្រត្យក្សនៃកិច្ចខិតខំប្រឹងប្រែងរបស់ចិនក្នុងការរួមចំណែកជំរុញអភិវឌ្ឍន៍តំបន់ និងសាកលលោក។ យើងដឹងហើយថា គំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ» នេះ គឺជាក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍក្នុងតំបន់ និងលើសាកលលោក និងជាយន្តការមួយដែលផ្តល់ធនធានដល់ប្រទេសនានាក្នុងសាកលលោកពិសេសប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់បំពេញគម្លាតតម្រូវការហិរញ្ញប្បទានដើម្បីបង្កើនការតភ្ជាប់។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានបន្តថា សម្រាប់កម្ពុជាគំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ» បានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមវប្បធម៌។ ភាពជោគជ័យនៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ដែលជាគម្រោងវិនិយោគដ៏ធំរបស់ចិន និងជាសក្ខីភាពមួយយ៉ាងច្បាស់នៃការកសាងគម្រោងផែនការសហប្រតិបត្តិការ «ខ្សែក្រវ៉ាត់ និងផ្លូវ» រវាងប្រទេសទាំងពីរ។ គម្រោងទាំងនេះទទួលបានជោគជ័យល្អប្រសើរហើយបច្ចុប្បន្នមានក្រុមហ៊ុនចំនួន១៦១កំពុងធ្វើសហប្រតិបត្តិការ។ ក្នុងនោះមានក្រុមហ៊ុនចិនចំនួន ១៤៨ និងបង្កើតការងារជូនប្រជាជនកម្ពុជាជាង ២ម៉ឺននាក់។ ការអភិវឌ្ឍសេដ្ឋកិច្ចក្រុងព្រះសីហនុ ជំហានពីរអាចនឹងបង្កើតការងារជូនប្រជាជនប្រមាណ ៤ ម៉ឺននាក់បន្ថែមទៀត។ សមិទ្ធផលថ្មីមួយទៀតតាមរយៈគំនិតផ្តួចផ្តើមនេះគឺកម្ពុជាសម្រេចបាននូវការកសាងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ដែលនឹងក្លាយទៅជាកម្លាំងចលករមួយចូលរួមកែប្រែវិមាត្រសេដ្ឋកិច្ចកម្ពុជា និងបង្កើនការតភ្ជាប់ក្នុងតំបន់ឱ្យកាន់តែប្រសើរឡើង ខុសប្លែកពីទស្សនៈមួយចំនួនដែលយល់ឃើញថា គំនិតផ្តួចផ្តើមនេះ នឹងបណ្តាលឱ្យប្រទេសមួយចំនួនជាប់អន្ទាក់បំណុល។ ប្រទេសកម្ពុជាមិនត្រឹមតែអាចចរចា និងរៀបចំគម្រោងនេះដោយឈរលើស្មារតីការពារផលប្រយោជន៍ជូនជាតិ និង ប្រជាជនរបស់ខ្លួនដោយស្មើភាព និងស្មើសិទ្ធិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចបាននូវការធ្វើវិស្វកម្មហិរញ្ញវត្ថុមួយដែលមិនបង្កើតបន្ទុកហិរញ្ញវត្ថុ និង

> ***គំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់និងផ្លូវ» នេះ គឺជាក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍក្នុងតំបន់ និងលើសាកលលោក និងជាយន្តការមួយដែលផ្តល់ធនធានដល់ប្រទេសនានាក្នុងសាកលលោកពិសេសប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់បំពេញគម្លាតតម្រូវការហិរញ្ញប្បទានដើម្បីបង្កើនការតភ្ជាប់។***

បំណុលសាធារណៈដល់រដ្ឋថែមទៀតផង។

ក្រៅពីគម្រោងនេះ ក៏នៅមានគម្រោងជាច្រើនទៀត ដែលគេដឹងថា ចិនកំពុងតែអនុវត្តនៅកម្ពុជា ដូចជានៅខេត្តកោះកុង ដែលគម្រោងអភិវឌ្ឍដ៏មហាសាលមួយ មានគម្រោងគ្រោងតាំងពី រីសត ព្រលានយន្តហោះ កំពង់ផែ រហូតដល់មាននូវទស្សនវិស័យមួយចំនួនគិតថា ក្រោមគំនិតផ្តួចផ្តើមនេះ កម្ពុជាកំពុងតែក្លាយជាផ្នែកមួយជាទីតាំងយុទ្ធសាស្ត្រយោធារបស់ចិននៅក្នុងតំបន់ ប៉ុន្តែរាជរដ្ឋាភិបាល ដោយឈរនៅលើរដ្ឋធម្មនុញ្ញ និងឯករាជ្យភាពរបស់ខ្លួន បានធានាអះអាងយ៉ាងប្រាកដថាទីនោះគ្មានហេតុផលយុទ្ធសាស្ត្រយោធាឡើយ គឺមានតែទេសចរណ៍ និងសេដ្ឋកិច្ច ព្រមទាំងពាណិជ្ជកម្មតែប៉ុណ្ណោះ។

សរុបសេចក្តីទៅ ទស្សនវិស័យមួយដែលគេបង្កើតទៅ វាតែងមានហេតុនិងផល ព្រមទាំងគោលបំណងនៃការរៀបចំសេដ្ឋកិច្ច និងទីតាំងភូមិសាស្ត្រនយោបាយដើម្បីចំណេញនិងទទួលបានផលប្រយោជន៍សម្រាប់ប្រទេសគេទាំងអស់ ប៉ុន្តែប្រសិនជាយើងឆ្លាត ហើយចេះរៀបចំនូវយុទ្ធសាស្ត្រសមស្របមួយដែលត្រឹមត្រូវ និងច្បាស់លាស់ ទោះបីនោះជាអ្វីដែលគេមានគំនិត ឬគោលបំណងយ៉ាងណា បើយើងចេះរៀបចំខ្លួននៅក្នុងការឆ្លើយតប និងចរចរណ៍ដោយស្មើភាព យើងខ្ញុំយល់ឃើញថា ការសម្រេចចិត្តចូលរួមដ៏សកម្មនៅក្នុងយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើម «ខ្សែក្រវ៉ាត់ និងផ្លូវ» នេះគឺជាឱកាសមួយ សម្រាប់កម្ពុជានៅក្នុងការអនុវត្តនូវទស្សនវិស័យនៃឆ្នាំ២០៣០ និងឆ្នាំ ២០៥០ ដែលកំណត់នៅក្នុងការលើកកំពស់សេដ្ឋកិច្ច និងពាណិជ្ជកម្មឈានទៅបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ បើយើងក្រហើយនៅតែស្រែកថា យើងក្រ មិនរួមសហការគ្នា គិតតែដេកត្អូញត្អែរថា យើងក្រ តើនៅពេលណាយើងមាន។ ជាការពិតមានប្រទេសមួយចំនួន កំពុងរអានឹងចូលរួមគំនិតផ្តួចផ្តើមនេះ ក្រោយពេលដែលប្រទេសមួយចំនួនបានក្លាយជាកូនបំណុលដែលគ្មានលទ្ធភាពដោះស្រាយបំណុលបានរហូតដល់ចិន រឹបអូសគម្រោងនានា ដែលមានប៉ុន្តែកម្ពុជាខុសគ្នា ដោយសារតែនៅពេលនេះ កម្ពុជាកំពុងតែ មានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ យើងមានបំណុលច្រើន តែវាកំពុងតែរក្សាបាននូវតុល្យភាពនៃ ប្រាក់ចំណូលពន្ធ និងសេដ្ឋកិច្ច នៅក្នុងការធានាសងរំលស់នូវបំណុលទាំងនេះបាន។ ហើយនៅពេលនេះ យើងក៏សង្ឃឹមថា គម្រោងរបស់រាជរដ្ឋាភិបាល នៅក្នុងការទាញមូលនិធិចេញពីគំនិតផ្តួចផ្តើមនឹង នឹងមានជាបន្តបន្ទាប់ទៀតសម្រាប់យកមកអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធដើម្បីបំពេញដល់គម្រោងការអភិវឌ្ឍពាណិជ្ជកម្មទេសចរណ៍ និងសម្រួលដល់ចលនារបស់ប្រជាជន និងពាណិជ្ជកម្ម៕



សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបពិភាក្សាការងារជាទ្វេភាគីជាមួយប្រធានាធិបតីចិន នៅក្នុងទីក្រុងប៉េកាំង។ រូបភាព៖ ហ្វេសប៊ុកសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន



សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងលោក លី ឃើជាំង នាយករដ្ឋមន្ត្រីសាធារណរដ្ឋប្រជាមានិតចិន។ រូបភាព៖ សហការី

# វិវាទពលរដ្ឋនៅខេត្តព្រះសីហនុ ទាក់ទងនឹងវត្តមានចិន




## ពលរដ្ឋកម្ពុជាពិតជាភ្ញាក់ផ្អើលនឹងស្ថានភាពជាក់ស្ដែងដែលមាននៅខេត្តព្រះសីហនុ ក្រោយវត្តមាននៃជនជាតិចិននៅលើទឹកដីនោះមានការកើតឡើងប្រមាណជា ៣ឆ្នាំចុងក្រោយមកនេះ។

*ដោយ៖ អរិយបុត្រ*

ឈរសម្លឹងមើលបណ្ដាសំណង់ដែលកំពុងតែមមាញឹកសាងសង់ នាការដ្ឋានសំណង់នានា នៅម្ដុំតោពីរ លោក ជុំ សុន្ទរៈ ដែលកំពុងតែឈរជក់បារី រង់ចាំគ្រួសារចូលទៅទិញឥវ៉ាន់បន្តិចបន្តួច មុនពេលទៅឆ្នេរ បានថ្លែងថា ក្រុងព្រះសីហនុនាពេលបច្ចុប្បន្ននេះ គឺប្លែកមែនទែន សំណង់ អាគារខ្ពស់ៗកើតមានព្រោងព្រាត ដែលធ្វើឲ្យលោកដំបូងឡើយសឹងតែមិនជឿថានេះគឺជា ទីក្រុងព្រះសីហនុ។

តាមការរៀបរាប់របស់លោក សុន្ទរៈ បានឲ្យដឹងថា ប្រសិនបើលោកមិនបានមកខ្លួនឯងហើយស្ដាប់តែគេនិយាយ គឺលោកពិតជាមិនជឿថា ទឹកដីនេះ ដែលពីមុនរកតែសំណង់លើសពី ១០ ជាន់ពិបាក នៅពេលនេះ គឺពេញទឹកពេញដី កន្លែងណាក៏មានអាគារដែរ ជាពិសេស នៅម្ដុំតោពីរនេះតែម្ដង។

លោកបានបញ្ជាក់ថា៖ «អូយហ៍ ខានមកតែ ២ឆ្នាំសោះ កំពង់សោម (ក្រុងព្រះសីហនុ) ឥឡូវនេះ ខុសគ្នាពីមុខឆ្ងាយណាស់។ បើមិនបានមកឃើញផ្ទាល់ទេ គឺរកជឿមិនចង់កើតពេលឮគេនិយាយនៅភ្នំពេញ»។

រហូតមកដល់ពេលនេះ ចាប់តាំងពីចុះពីចំណោទកន្លែងដែលចោទបំផុតហើយមកដល់ចំណុចស្ថានីយប្រេងពីរ គឺ ស្ថានីយប្រេងឥន្ធនៈតេឡា និង ស្ថានីយប្រេងឥន្ធនៈសូគីមិច (ទុកចោល) ទីណាក៏ឃើញតែការដ្ឋានសំណង់ ដែលការដ្ឋានទាំងនោះ មិនមែនសង់ផ្ទះល្វែងទេ គឺជាសំណង់ អាគារខ្ពស់ៗ។ ហើយប្រសិនបើយើងឡើងទៅរកចំណុចកូនភ្នំនៅក្នុងទីក្រុងនេះហើយពិនិត្យ មើលទិដ្ឋភាពទាំងនេះ យើងឃើញថា ការដ្ឋានសំណង់ និងគ្រោងអគារកកើតឡើងប្រៀបបាន និងផ្សិតដុះពេលត្រូវទឹកសន្សើម ឬទឹកភ្លៀងដើមរដូវ។

អ្នកនាំសារមិនអាចទំនាក់ទំនងសុំការបំភ្លឺពីអាជ្ញាធរនៅក្រុងព្រះសីហនុ បានទេ ប៉ុន្តែប្រជាពលរដ្ឋ និងអាជីវករខ្មែរដែលកំពុងតែរស់នៅ និងប្រកបរបររកស៊ី នៅទីនោះ បានអះអាងថា ម្ចាស់ការដ្ឋាន និង សំណង់អាគារទាំងនេះ គឺសុទ្ធតែជារបស់ក្រុមហ៊ុនចិន ពោលគឺចិន ជាអ្នកសាងសង់ទាំងអស់។

លោក គួង សារឹម ដែលជាអ្នកបើករថយន្តតាក់ស៊ី នៅក្រុងព្រះសីហនុ បានអះអាងថា ទីណាក៏មានការដ្ឋានសំណង់ដែរ នៅក្រុងព្រះសីហនុឥឡូវនេះ។ លោកបានបន្តថា កន្លែងខ្លះគ្មានកម្មសិទ្ធិផង ពោលគឺបានត្រឹមតែជួលគេ ៣០ ទៅ៤០ ឆ្នាំ ក៏ចិនបើកការដ្ឋានសាងសង់ដែរ។

លោកបានបញ្ជាក់ថា៖ «ខ្ញុំមិនយល់មិនដឹងគេធ្វើស្អីគេ! ដីទំនេរខ្លះ ដែលមានទំហំធំល្មមចិនហ៊ានជួលគេ ២ទៅ៣ម៉ឺនដុល្លារ ហើយយកទៅសង់អាគារដែរ... មិនយល់មិនដឹងជាគេមកធ្វើអ្វី? អគារខ្លះ ចេញគ្រោងចេញរូបរាង អត់មានសកម្មភាពទេ តែឃើញមានលើកស្លាកដាក់ជួល»។

លោកបានបន្តទៀតថា ភាគច្រើនសំណង់ដែលឃើញសាងសង់រួច ដូចជានៅម្ដុំឆ្នេរឯករាជ្យ ចុះមក អ៊ី គឺ គេបើកជាសណ្ឋាគារ ជារីសត និងកាស៊ីណូ ខ្លះជាខុនដូរ តែអគារភាគច្រើននៅមិនទាន់សាងសង់រួចទេ ។

លោកបានបន្តទៀតថា គ្រប់ឆ្នេរទាំងអស់ គឺសុទ្ធតែមាន ការដ្ឋានសំណង់ចិនទាំងអស់។ មិនថា តែអូរឈើទាល ឯករាជ្យ អូត្រេះ អី គឺសុទ្ធតែការដ្ឋានរបស់ក្រុមហ៊ុនចិន សាងសង់។

ទាក់ទិននឹងវត្តមាននៃកំណើនជនជាតិចិនទាំងនេះ លោក សារឹម បានអះអាងថា វាពិតជាងាយស្រួលមែន ពីព្រោះលោកសំបូរអតិថិជន ហើយនៅក្នុងមួយថ្ងៃ ផាត់សាំង ផាត់ហ្គាស អីទៅ គឺលោកអាចនៅសល់ប្រាក់ ប្រមាណជា ២០ ទៅ ២៥ ដុល្លារដែរ។

លោក សារឹម ដែលពីមុនធ្លាប់បើករថយន្តឲ្យគេនៅភ្នំពេញ បានថ្លែងថា ទាក់ទិននឹងរឿងមុខរបរ និងប្រាក់ចំណូលអី គឺប្រសើរជាងមុន ហើយ ភរិយារបស់លោក ដែលមានរបរលក់ដូរ ក៏ប្រសើរដែរ ប៉ុន្តែបើនិយាយអំពីអារម្មណ៍វិញ គឺថា លោកពិបាកពណ៌នា។

អ្នករត់ទុកៗមួយរូប ដែលកំពុងតែឈរជិតលោក សារឹម តែមិនបានអះអាងអត្តសញ្ញាណនោះទេបានបន្ថែមថា៖ «គេ( ភ្ញៀវទេសចរចិន) មិនធ្វើអីយើងទេ។ គេវៃគ្នាតែគ្នាគេទេ តែខ្ញុំដូចជាមិនសូវចូលចិត្តចរិតពួកគេ»។

លោកបានបន្តទៀតថា ពួកគេនោះរញ៉េរញ៉ៃ ហើយបើនិយាយពីបើកបរវិញ គឺគ្មានច្បាប់គ្មានទម្លាប់ស្អីទេ ចតក៏ដូចគ្នាដែរ ចង់ទើសអ្នកណាក៏ទើសទៅ តែថាគាត់ឈប់ហើយ គឺឈប់ហើយ។

លោកបន្តទៀតថា ភ្ញៀវទេសចរអឺរ៉ុបឥឡូវស្ងាត់ឈឹងតែម្ដង បើមក ឃើញមួយៗទេ ពោលគឺចង់៨០ទៅ ៩០ ភាគរយហើយជាភ្ញៀវទេសចរចិន។

លោកបានអះអាងថា៖ «ឆ្នាំមុនៗ ខ្ញុំដឹកតែភ្ញៀវបារាំង ឥឡូវ ជួនកាលមួយអាទិត្យអី ទើបប៉ះបារាំង (ភ្ញៀវទេសចរមកពីលោកខាងលិច) ម្ដង។ ឥឡូវនេះសុទ្ធតែចិន»។

ជុំវិញវត្តមាននៃភ្ញៀវទេសចរមកពីអឺរ៉ុបនេះ លោក សារឹម បានឲ្យដឹងថា ស្ងាត់មែនទែន។ ពីមុន នៅម្ដុំអូរឈើទាលអី សំបូរហាងបារាំងណាស់។ឥឡូវនេះស្ងាត់បាត់អស់ហើយ ក្រោយមក ក៏ឃើញមានខ្លះនៅអូត្រេះ តែ ពេលភ្ញៀវទេសចរចិន ទៅដល់ទីនោះដែរ អូត្រេះឥឡូវ ក៏ស្ងាត់ភ្ញៀវអឺរ៉ុបដែរ។

លោកស្រី គួន គីម ជាអ្នកប្រកបរបរលក់ភេសជ្ជៈមួយកន្លែង បានអះអាងថា ការរកស៊ីវ៉ាមិនជាអ្វីទេ ប៉ុន្តែនៅក្នុងនាមជាអាជីវករលក់ដូរតូចតាចដូចលោកស្រី ពិបាកជាងមុន ជាពិសេស រឿងការបញ្ជាទិញ ទំនិញមួយចំនួនសម្រាប់គាត់យកលក់។

លោកស្រី បានបញ្ជាក់ថា ការលក់ដូរលោកស្រី មិនជាអ្វីទេ ចេះតែទៅមុខ ប៉ុន្តែខ្វាងលំបាក រឿងហៅគេដឹកឥវ៉ាន់សម្រាប់លក់ឲ្យយើង។

លោកស្រី បានបញ្ជាក់ថា៖ «យើងអ្នកលក់តូចតាច បែបនេះ ឥឡូវគេមិនសូវចាប់អារម្មណ៍យើងទេ។ យើងហៅគេដឹកទឹកកក ដឹកភេសជ្ជៈអីមកឲ្យយើង ពេលខ្លះ គេមិនដឹកឲ្យទេ។ ពេលខ្លះមួយអាទិត្យអីទៅ គេចាប់អារម្មណ៍ដឹកឲ្យតែហាងធំៗ ហាងចិន ហាងអីឯណោះ»។

លោកស្រី ដែលមកពីខេត្តកំពត ហើយបានមកស្នាក់នៅ និងជួលផ្ទះបងប្អូន រកស៊ីនេះ បានត្អូញត្អែរថា លោកស្រី និងគ្រួសារមិនទាន់ដឹងថាម៉េចទេ ពីព្រោះឥឡូវបងប្អូនក៏ដូចជា ចង់ជួលឲ្យចិនដែរ ព្រោះគេហ៊ានឲ្យថ្លៃ។

លោកស្រី បានបញ្ជាក់ថា៖ «តូបខ្ញុំអត់អីទេ ដោយសារខ្ញុំលក់នៅចិញ្ចើមផ្លូវ តែយ៉ាប់កន្លែងស្នាក់ ដោយសារផ្ទះដែលនៅរាល់ថ្ងៃនេះ មួយខែ ២០០ ដុល្លារ ឥឡូវចិនគេមកសុំ គាត់ជួលហើយ។ ចិនគេថា បើបងប្អូនខ្ញុំនិងខ្ញុំរើចេញ គេហ៊ានជួល មួយខែ ២០០០ដុល្លារ»។

លោកស្រីបានបន្តទៀតថា លោកស្រី មិនទាន់ដឹងថា ត្រូវទៅស្នាក់នៅទីណាទេ ពីព្រោះឥឡូវនេះ ផ្ទះជួលនៅកំពង់សោមឥឡូវថ្លៃណាស់ ហើយនៅកណ្ដាលក្រុង ចិនជួលចង់ ៧០ ទៅ ៨០ ភាគរយអស់ហើយ។

ទាក់ទិននឹងការចំណាយរឿងហូបចុក និងស្នាក់នៅវិញ លោក សុន្ទរៈ ដែលជាភ្ញៀវទេសចរនៅក្នុងស្រុក កំពុងតែនាំគ្រួសារមកកំសាន្តខាងលើ បានអះអាងថា ថ្លៃឥឡូវនេះ ផ្ទះសំណាក់ដែលពីរឆ្នាំមុន ត្រឹម ១០ ទៅ ១៥ ដុល្លារអីរកលែងមានហើយ គឺថោកបំផុត ក៏ ៤០ដុល្លារដែរ។

លោកបានបន្តទៀតថា រឿងហូបចុកក៏ដូចគ្នាដែរ នៅមាត់សមុទ្រអី ម្ហូប មួយចាន បើគ្មានពី ១០ ទៅ ១៥ដុល្លារទេ រកស្អីហូបគ្មានឡើយ។ លោកបានលាន់មាត់ថា៖ «ទីនេះឥឡូវ ស្អីក៏ចង់ដូចមាសដែរ»៕





*ជនជាតិចិនដែលបង្កហឹង្សានៅក្រុងព្រះសីហនុត្រូវបានអាជ្ញាធរបង្ក្រាបនាពេលកន្លងមក។ រូបភាព៖ សហការី*





# បញ្ហាដាច់ចរន្តអគ្គិសនី នៅតែជាប្រធានបទដ៏ក្ដៅគគុក



*ឯកឧត្តម កែវ រតនៈ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកអគ្គិសនីកម្ពុជា។ រូបភាព៖ EDC*

*ដោយ៖ អរិយបុត្រ*

បញ្ហានៃការដាច់ចរន្តអគ្គិសនីនៅរាជធានីភ្នំពេញរហូតមកដល់ពេលនេះ វាបានក្លាយជាប្រធានបទមួយ ដ៏ក្ដៅគគុកដែលសាធារណៈជនទូទៅកំពុងតែលើកយកមកដោយ ពីពេលមុនដាច់តែពេលថ្ងៃទេ ប៉ុន្តែពេលនេះ សូម្បីតែពេលយប់ក៏ដាច់ដែរនៅតំបន់ខ្លះ។

លោក រុន ទេពវាសនា ជាប្រជាពលរដ្ឋដែលរស់នៅ ម្ដុំសង្កាត់បឹងទំពុន ខណ្ឌមានជ័យ បានសំដែងយោបល់ដោយចំងល់ផង និងដោយភាពក្រេវក្រោធបន្តិចថា៖ «ខ្ញុំឆ្ងល់ដែរ មិនដឹងយ៉ាងម៉េច ប៉ុន្មានយប់នេះ ភ្លើងនៅម្ដុំផ្ទះខ្ញុំចេះតែដាច់រហូត»។

តាមការរៀបរាប់របស់លោក ទេពវាសនា វាពិតជាឆ្ងល់មែន ពីព្រោះរវាងម្ដុំផ្ទះរបស់លោក គឺម្ខាងដាច់ ម្ខាងទៀតគេមានភ្លើងប្រើប្រាស់រហូតរបស់គេ។

លោកបានបន្តទៀតថា៖ «មិនឲ្យឆ្ងល់ម៉េច បើរស់នៅម្ដុំគ្នា គេឆេះយើងមិនឆេះ។ ហ៊ឺ ឲ្យតែយ៉ាងនេះ មិនដឹងរកស៊ី ធ្វើការស្អីកើតទេ ដាច់ឆេះៗ តែអីចឹងរហូតនោះ»។

ការរអ៊ូរទាំងនេះ មិនមែនកើតមានឡើងតែលោក ទេព វាសនា នោះទេ ដោយសារ តែការដាច់ចរនអគ្គិសនីជាបន្តបន្ទាប់ជាពិសេសពេលរាត្រីនេះ បានកកើតមាននៅតំបន់ជាច្រើនកន្លែង នៅប៉ែកខាងលិច រាជធានីភ្នំពេញ រួមទាំងតំបន់ភ្នំពេញថ្មី តំបន់ចំការដូង ហើយសូម្បីតែមន្ទីរពេទ្យព្រះកុសមៈ ក៏មានបញ្ហាដាច់ចរនអគ្គិសនីផងដែរ។

លោកស្រី ទេព កេសរ ជាស្ត្រីមេផ្ទះមួយរូប នៅម្ដុំស្ពានដែក នៅចំការដូង បានឲ្យដឹងថា បន្ទាប់ពីមានភ្លៀងមួយមេ ថា ដោយសារ តែបញ្ហាភ្លើងវារអាក់រអួលនេះលោកស្រីនិងក្រុមគ្រួសារកំពុងតែមានបញ្ហាសុខភាព។

លោកស្រី បានរៀបរាប់ថា មួយយប់ៗលោកស្រី គេងបានត្រឹមតែមួយម៉ោង ទៅ ២ម៉ោងទេ ដោយសារតែបញ្ហាដាច់ភ្លើងនេះ។ ចឹងហើយឥឡូវរង្វង់ភ្នែកឡើងខ្មៅហើយខូងទៀត។

លោកស្រីបានបញ្ជាក់ថា៖ «គេងម៉េចបានបើក្រុមគ្រួសារលោកស្រីធ្លាប់គេងម៉ាស៊ីនត្រជាក់ តែនេះភ្លើងដាច់ហើយដាច់ទៀត តាំងពីក្រោយចូលឆ្នាំហើយមក។អាកាសធាតុក្ដៅឡើង ៤០ជាង គ្រាន់តែញើសក៏ហូរមកចង់ខ្សោះខ្លួនដែរ ចឹងហើយមួយយប់ៗ ខ្លួនឯងគេងមិនលក់ ចេះតែឡើងបក់ឲ្យកូន។ អាណិតពួកគេ គ្នាក្មេង»។

លោកស្រីបានបញ្ជាក់ថា៖ «មួយយប់ៗ ពេលដាច់ភ្លើង ចេះតែចង់ទៅគេងអូតែលទេ តែចេះតែខ្លាចទុកផ្ទះចោល ខ្លាចពួកចោរពួកអី ឆ្លៀតឱកាសហើយក៏ចេះតែខំប្រឹងទ្រាំទៅ»។

លោក សាញ់ ជំនិត ជាអ្នកដំណើរដែលកំពុងតែស្រស់ស្រូបអាហារពេលព្រឹកនៅម្ដុំ ស្ពានដែក នៅចំការដូងនោះដែរ បានបន្ថែមថា វាជាបញ្ហាហើយ រឿងដាច់ថ្ងៃ តែឥឡូវវាថែមទាំងដាច់យប់ ទៀត ហើយមិនត្រឹមតែប៉ុណ្ណឹងទេ ថែមទាំងដាច់ទឹកទៀត។

លោកបានបន្តទៀតថា លោកពិតជាមិនយល់រឿងនេះ! ថា ដាច់ពេលថ្ងៃចុះវាចង់សុំ ហើយពេលនេះតែ អាដាច់យប់នេះពិបាកដេកពិបាកពួនណាស់។

លោកបញ្ជាក់ថា៖ «ដាច់ពេលថ្ងៃវាមធ្យមទេ ប៉ុន្តែឥឡូវនេះវាធំខ្លាំងពេលដែលដាច់យប់ ហើយមិនត្រឹមតែ ដាច់ភ្លើងទេ ទឹកក៏ដាច់ទៀត»។

ការរអ៊ូរទាំអំពីការដាច់ចរន្តអគ្គិសនី ដែលពលរដ្ឋសាមញ្ញតែងតែនិយាយថា ភ្លើងនេះគឺកើតមាននៅពេលថ្ងៃនៅក្នុងរង្វង់ប្រមាណជាជាងមួយខែមកហើយ ដោយសារតែកង្វះខាតថាមពល ដែលបណ្ដាលមកពីអាកាសធាតុក្ដៅខ្លាំង បណ្ដាលឲ្យទំនប់វារីអគ្គីសនីដែលជាផុងអាគុយនៃចរនអគ្គិសនីនៅក្នុងប្រទេសមានបញ្ហាមិនអាចដំណើរការដោយរលូនបាន។ ហើយអ្នកជំនាញខាងអគ្គីសនីក៏បានលើក ឡើងថា ជារួមនៅពេលនេះកម្ពុជាកំពុងតែប្រឈមមុខនឹងកង្វះខាតអគ្គីសនីប្រមាណជា ៤០០ មេហ្គាវ៉ាត។ ប៉ុន្តែនៅក្នុងអំឡុងពេលប្រហែលជា ១០ ថ្ងៃមកនេះ តំបន់ខ្លះ ក្រៅពីដាច់ពេលថ្ងៃហើយនោះ សូម្បី តែពេលយប់ក៏នៅតែរអាក់រអួល ហើយពេលខ្លះគឺដាច់ពេញមួយយប់ក៏មានផងដែរ។

ការដាច់ចរន្តពេលថ្ងៃកន្លងមកប្រជាពលរដ្ឋរអ៊ូពីការធ្លាក់ចុះនៃប្រាក់ចំណូល ខូចខាតសំភារៈ ប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិត ប៉ុន្តែពេលជួបប្រទះនូវបញ្ហាដាច់ពេលរាត្រីបន្ថែមទៀតនេះ គឺរិតតែធ្វើឲ្យពួកគេ រអ៊ូថែមទៀត គឺប៉ះពាល់ដល់សុខភាព។



*ក្រុមអ្នកបច្ចេកទេសចុះពិនិត្យទីតាំងប្រអប់អគ្គិសនីអ្នកប្រើប្រាស់ដែលមានបញ្ហាកើនគីឡូ បើទោះបីជាភ្លើងត្រូវបានកាត់ផ្ដាច់ការផ្គត់ផ្គង់ញឹកញ៉ាប់។ រូបភាព៖ EDC*

យោងទៅតាមសេចក្ដីជូនដំណឹងរបស់អគ្គីសនីកម្ពុជា ជាបន្តបន្ទាប់ នៅក្នុងរង្វង់ប្រមាណជាជាងមួយសប្ដាហ៍កន្លងមកនេះ គឺដោយសារតែមានឧបទ្ទវហេតុផ្ទុះដាច់ខ្សែរកាបបណ្ដាញតង់ស្យុងមធ្យម ដែលហៅភាសាបញ្ចេកទេសថា MV ក្រោមដីចេញពីអនុស្ថានីយមួយចំនួនជាបន្តបន្ទាប់បន្តកន្ទុយគ្នា។

ជុំវិញបញ្ហាដាច់ចរនអគ្គិសនីនៅពេលយប់នេះ អ្នកបច្ចេកទេសអគ្គីសនីកម្ពុជាដែលកំពុងតែបំពេញកិច្ចការនេះ បាននិយាយប៉ុន្មានម៉ាត់ដោយខ្លីៗ ក្រោមកំដៅដ៏ក្ដៅ លាយឡំដោយញើសពេញផ្ទៃមុខ ថា នេះគឺជារឿងបច្ចេកទេសមែន ខាងខ្ញុំចេញពីកន្លែងអស់ហើយ ដោយម្នាក់នៅតាមកាប៊ិន និងកន្លែងដែលមានបញ្ហា។

លោកបានបញ្ជាក់ដោយថ្លៃថា៖ «ម៉ាយប់អ្នកបច្ចេកទេសប្រចាំការ មិនបានដេកមិនបានពួនដូចគ្នា ប៉ុន្តែយើងខ្ញុំនឹងខិតខំបង»៕



*បុគ្គលិកជំនាញជួសជុលបណ្ដាញចែកចាយអគ្គិសនី។*



*ការជួសជុលឧបករណ៍ដើម្បីភ្ជាប់ចរន្តឡើងវិញ។ រូបភាព៖ EDC*



*ឧបករណ៍បណ្ដាញអគ្គិសនីដែលរងការខូចខាតកន្លងមក។ រូបភាព៖ EDC*

# ស្ត្រីសម័យថ្មី សង្ស័យលែងមានម្ជុរ អំបោះក្នុងផ្ទះហើយ



**ការដេរប៉ាក់ចាក់ចុលក្នុងផ្ទះ ជាតួនាទីមួយរបស់ស្ត្រីមេផ្ទះកាលពីជំនាន់មុន ប៉ុន្តែសម័យនេះ នារីខ្មែរមួយចំនួនធំមិនសូវចេះកិច្ចការងារនេះទៀតទេ ព្រោះប្រហែលគាត់គិតថា ការងារនេះ អាចជួលដល់ជាងកាត់ដេរដែលមានជាច្រើនកន្លែងនៅក្បែរផ្ទះរបស់គាត់រស់នៅ។ ម្យ៉ាងវិញទៀតនៅក្នុងផ្ទះ ក៏គ្មានអ្នកបង្រៀនដូចសម័យមុនដែលស្ត្រីត្រូវចូលក្នុងម្លប់ដើម្បីរៀនអំពីវិជ្ជាមេផ្ទះនិងគ្រប់កិច្ចការងារក្នុងផ្ទះទាំងអស់ តាំងពីដាំស្ល ដេរសម្លៀកបំពាក់ ត្បាញខោអាវ ឬមើលថែរក្សាកូននិងប្តីជាដើម។ វប្បធម៌នេះបានប្រែប្រួលតាមកាលៈទេសៈរបស់មនុស្សដែលរស់នៅក្នុងសម័យនេះ។ អ្នកខ្លះក៏ចេះ អ្នកខ្លះទៀតក៏មិនចេះ។**

*ដោយ៖ រឿង ស្រីម៉ាច*

ម្ជុរនិងអំបោះគឺជាវត្ថុដែលស្ត្រីមេផ្ទះជំនាន់មុនតែងរក្សាទុកក្នុងផ្ទះនីមួយៗមិនដែលចោលទេ ជាពិសេសស្ត្រីនៅតាមទីជនបទតែងតែទុកដាក់គ្រាន់ប៉ះសម្លៀកបំពាក់ ឬមុង ភួយ រហែកបន្តិចបន្តួចដោយមិនចាំបាច់ត្រូវការជាង គឺគេដេរដោយដៃ។ សម័យថ្មីមានភាពងាយស្រួលព្រោះមានម៉ាស៊ីនទំនើប និងហាងកាត់ដេរគ្រប់ទីកន្លែង។ ចុះស្ត្រីមេផ្ទះសព្វថ្ងៃនេះនៅចេះដេរដោយដៃទៀតទេ?

អ្នកស្រី ដួង ស្រីពីន វ័យ ២៥ឆ្នាំជាគ្រូមត្តេយ្យកម្រិតមួយនៅទីក្រុងភ្នំពេញបានឱ្យដឹងថា ពេលខ្លះមានអារម្មណ៍ថាខ្វះខ្វាយខ្លះដែរ ព្រោះពេលមានសម្លៀកបំពាក់ប្តីឬកូនរហែកអីគឺក្រៅតែពីយកឱ្យជាងដេរគឺបត់ទុកចោលហើយទៅរកទិញថ្មី តែបើចេះដេរគឺរបស់នោះអាចប្រើបានវិញ។

ស្រីពីនបន្តថា៖ «តាំងពីដើមមកមិនដែលយកចិត្តទុកដាក់រៀនដេរដៃពីម៉ាក់ទេហើយក្នុងផ្ទះវិញក៏អត់មានម្ជុរអំបោះអីដែរ ព្រោះគិតថាអត់ចេះដេរ ដូច្នេះមិនដឹងទិញទុកមកធ្វើអី?»។

អ្នកស្រី ដួង ស្រីពីនបន្ថែមថា៖ «មានអារម្មណ៍ស្តាយក្រោយដែលមិនបានយកចិត្តទុកដាក់កិច្ចការបន្តិចបន្តួចនេះហើយអន់ចិត្តខ្លះដែរ នៅពេលប្តីថាស្រីនឹងគេដែលអត់ចេះដេរខោអាវ»។

មិនសូវខុសគ្នាពីស្ត្រីខាងលើ អ្នកស្រីកែវ លក្ខណា វ័យ៣០ឆ្នាំជាអាជីវករលក់បន្លែនៅផ្សារបានឱ្យដឹងថាសម័យនៅក្មេងៗ ម្តាយរបស់គាត់តែងដេរខោអាវដោយដៃឱ្យគាត់ពាក់។ អ្នកស្រីបញ្ជាក់ថា៖ «ថ្នេរខោអាវគាត់ដេរគឺស្អាតដូចដេរម៉ាស៊ីនចឹង។ តែខ្ញុំវិញដេរមិនត្រង់ជួរទេ ជួនកាលមុតដៃដោយសារដេរនោះផងក៏មានចឹងទៅម្ជុរអំបោះក្នុងផ្ទះទុកចោលមិនដែលប៉ះតែម្តង»។

ស្ត្រីរូបនេះបន្ថែមថា៖ «ពេលខ្លះគិតថាបើជំនាន់ខ្ញុំជាម្តាយមិនចេះកិច្ចការកាត់ដេរជាលក្ខណៈគ្រួសារនេះផងទម្រាំកូនៗខ្ញុំរឹតតែមិនអើពើទៀតហើយ។ ចឹងជាការគួរ ស្ត្រីជាម្តាយគួរតែឆ្លៀតពេលបង្រៀនកូនខ្លះៗអំពីវិជ្ជាមេផ្ទះកុំឱ្យធំឡើងអត់ចេះអីដូចខ្ញុំ»។

ស្ត្រីចំណាស់វ័យ៧៣ឆ្នាំ លោកយាយ តៅ ឆ្នួន រស់នៅភ្នំពេញបានចែករំលែកពិសោធន៍កាលពីជំនាន់របស់គាត់ថា ពីដើមឡើយគ្រួសារនីមួយៗមិនសូវមានប្រាក់កាសច្រើនទេ ហើយការដេរដោយដៃនេះ ក៏អាចសន្សំប្រាក់បានយ៉ាងច្រើនដែរ។ ហើយនៅក្នុងផ្ទះនីមួយៗក៏តែងតែមានម្ជុរអំបោះទុកដាក់ជាប្រចាំ។

លោកយាយឆ្នួនមានប្រសាសន៍ទៀតថា៖ «ព្រោះពេលខោអាវប្តីហែកយើងជាស្រីតែងតែយកមកប៉ះប៉ូវឱ្យជិតៗ មុង ភួយ ខ្នើយ រហែកក៏ត្រូវប៉ះវាឱ្យជិត ព្រោះយើងគ្មានលុយទៅទិញរបស់ថ្មីតាមចិត្តអ្វីដែលអាចធ្វើបានយើងធ្វើ»។

លោកយាយឆ្នួនថា រហូតដល់ចាស់ចំណាស់នេះ លោកយាយក៏មិនចូលការដេរប៉ាក់ដោយដៃដែរ ទោះបីភ្នែកមើលមិនឃើញគឺពាក់វ៉ែនតា។ លោកយាយបន្ថែមថា៖ «កូនៗសម័យនេះគេរវល់រកស៊ី ធ្វើការ គឺមិនចេះធ្វើកិច្ចការផ្ទះសំបែងទេ។ ខ្ញុំខ្លាចទៅថ្ងៃខាងមុខទៀតស្ត្រីខ្មែរលែងចេះធ្វើកិច្ចការអ្វីដោយខ្លួនឯង គឺប្រើទឹកលុយទាំងអស់ធ្វើឱ្យក្មេងជំនាន់ក្រោយកាន់តែមិនចេះថែមទៀត ព្រោះអ្វីៗក៏ទំនើប»។



លោក ម៉ៅ តារា វ័យ ៤១ ឆ្នាំជាជាងកាត់សម្លៀកបំពាក់ម្តុំបឹងទំពុន នារាជធានីភ្នំពេញបានឱ្យដឹងថា រាល់ថ្ងៃលោកមមាញឹកខ្លាំងដែរ ព្រោះមានមនុស្សមកកាត់និងដេរ តម្រឹមជើងខោ បញ្ចូលអាវ ដាក់រ៉ូត ជាដើម ដែលភ្ញៀវមានទាំងស្រីនិងប្រុស ។

លោក តារានិយាយថា ក្រៅតែពីទទួលការបញ្ជាកាត់ពីភ្ញៀវ លោកនៅរកចំណូលបានច្រើនល្មមដែរ ពីការងារកំប៉ិកកំប៉ុកខ្លះដោយលោកមិនបានប្រើម៉ាស៊ីនទេ គឺដេរដោយដៃក៏រកលុយបានដែរយ៉ាងហោចណាស់ ៤ម៉ឺនទៅ ៥ម៉ឺនរៀលក្នុងមួយថ្ងៃ។

តាមយោបល់របស់លោកតារា បើស្ត្រីចេះដេរដោយដៃតិចតួចនៅផ្ទះក៏ល្អ ព្រោះមិនសូវចំណាយលុយទៅលើជាងដេរចំពោះរបស់រហែកបន្តិចបន្តួច ហើយណាមួយវាមិនយូរទេ គ្រាន់តែចំណាយពេលបន្តិចដេរគឺបានហើយ ធ្វើឱ្យប្តីសប្បាយចិត្តទៀត ព្រោះគេគិតថាប្រពន្ធយកចិត្តទុកដាក់លើកិច្ចការតិចតួចណាមួយបើយកឱ្យជាងគេដេរតិចពេកគេមិនទទួល ហើយជួនកាលត្រូវរង់ចាំយូរទៀតផង។ ដូចនេះចំពោះកាងារនេះស្ត្រីមេផ្ទះគួរតែចេះ៕





# ការរៀបចំសម្លៀកបំពាក់ស្វាមី

**ស្ត្រីជាភរិយាមួយចំនួនមិនសូវជាយកចិត្តទុកដាក់ប៉ុន្មានទេចំពោះសម្លៀកបំពាក់របស់ស្វាមីរបស់នាង។ ស្ត្រីខ្លះគិតថាប្តីគ្មានឋានៈ ឬគ្មានការងារធ្វើធំដុំមិនចាំបាច់រៀបចំសម្លៀកបំពាក់ឲ្យល្អប្រសើរឡើយ។ ប៉ុន្តែបុរសមួយចំនួនយល់ថាកិច្ចការងារតូចតាចនេះ គឺជាសេចក្តីសុខរបស់គាត់ ព្រោះប្រពន្ធចាប់អារម្មណ៍និងស្រលាញ់គាត់។**



*ដោយ៖ រឿន ស្រីម៉ាច*

ការស្លៀកពាក់ជារឿងមួយសំខាន់ណាស់ពីព្រោះវាបង្ហាញពីលក្ខណៈនៃការយកចិត្តទុកដាក់របស់បុគ្គលម្នាក់ៗ។ តួយ៉ាងភរិយាមាននាទីជាអ្នករៀបចំខោអាវឲ្យស្វាមីរបស់ខ្លួន ដែលអាចសបញ្ជាក់អំពីលក្ខណៈសម្បត្តិរបស់នាងបានយ៉ាងងាយ តាមរយៈសម្លៀកបំពាក់របស់ប្តី។

អ្នកស្រី វ៉ាន់ ស្រីវីង វ័យ ២៧ ឆ្នាំ ប្រកបរបរជាជាងកាត់សម្លៀកបំពាក់នៅទីក្រុងភ្នំពេញបានឲ្យដឹងថា ទោះបីជារវល់នឹងកិច្ចការរកស៊ីយ៉ាងណាក្តី ក៏កិច្ចការចាំបាច់មួយរបស់គាត់គឺរៀបចំសម្លៀកបំពាក់ជូនស្វាមីទៅធ្វើការងារជាកត្តាសំខាន់។

អ្នកស្រីបញ្ជាក់ថា៖ «ឃើញថាគាត់ងាយស្រួលក្នុងការរៀបចំខ្លួនចេញទៅធ្វើការដោយមិនចំណាយពេលរក រឺ អ៊ុតជាដើម។ គាត់ទៅធ្វើការទាន់ហើយមានអារម្មណ៍សប្បាយចិត្តទៅតាមនោះដែរ»។

អ្នកស្រីបន្ថែមទៀតថា៖ «ហេតុនេះទោះបីជារវល់ខ្លាំងក្តីក៏ឆ្លៀតពេលខ្លះដើម្បីរៀបចំខោអាវសម្រាប់ធ្វើការឲ្យគាត់ជាមុនដែរ ព្រោះវាជាភាពស្អាតនិងថ្លៃថ្នូរសម្រាប់ស្វាមី»។

ឆ្លងតាមបទពិសោធន៍របស់អ្នកស្រី ដិន ដានី វ័យ ៤០ ឆ្នាំជាស្ត្រីមេផ្ទះនៅខេត្តកំពង់ចាមបានឲ្យដឹងថា ពីមុន គាត់មិនសូវរវីរវល់នឹងការស្លៀកពាក់របស់ប្តីនោះទេ ព្រោះគាត់គិតថាប្តីមិនមានមុខនាទីធ្វើការធំដុំដូចគេ ហេតុនេះ គ្រួសាររបស់គាត់មានអ្វីចេះតែស្លៀកទៅ។

អ្នកស្រី បន្ថែមថា៖ «ពេលគាត់ទៅណាមកណាម្តងៗ គឺរអ៊ូរទាំរកនេះខ្វះនោះជាដើម។ តែមួយរយៈក្រោយនេះខ្ញុំបែរចេះរៀបចំខោអាវឲ្យប្តី ទោះខោអាវនៅផ្ទះរឺទៅចូលរួមពិធីគឺធ្វើការបោកគក់ស្អាតៗ រៀបចំបត់ដាក់ក្នុងទូឲ្យមានរបៀប»។

អ្នកស្រីបានរំលឹកថា គាត់ស្ទើរតែខ្មាសគេទាំងពីរនាក់នៅក្នុងពិធីមង្គលការអ្នកភូមិជាមួយគ្នាមួយ ព្រោះការតុបតែងខ្លួនរវាងប្តីនិងប្រពន្ធគឺដូចមេឃនិងដី។ អ្នកស្រីដានី៖ «ប្រិតព្រាងតុបតែងតែខ្លួនឯងស្អាត តែមើលមកប្តីអាវមិនអាវ ខោមិនខោ ធ្វើឲ្យគាត់សឹងតែមិនទៅចូលរួមក្នុងពិធីជាមួយដោយសារខ្មាសគេពេក»។

បើនិយាយអំពីការរៀបចំសំលៀកបំពាក់អ្នកស្រីកែវ ជីវ៉ា វ័យ ៣៥ឆ្នាំ ជាអ្នកភ្នំពេញបានឲ្យដឹងថា តាមទម្លាប់របស់អ្នកស្រី គឺមានការបែងចែកកន្លែងដាក់សម្លៀកបំពាក់ប្តីប្រពន្ធដាច់ដោយឡែកពីគ្នា ដើម្បីកុំឲ្យឡូកឡំពេលរក និងដើម្បីចំណេញពេលវេលា។

អ្នកស្រី ជីវ៉ាបន្តថា៖ «សម្លៀកបំពាក់ប្តីសម្រាប់ធ្វើការគឺខ្ញុំបោកសម្អាត និង អ៊ុតដាក់ក្នុងទូ ចំណែកខោអាវធម្មតា គឺបត់ឬព្យួរស្អាអាវដាក់ក្នុងទូរកន្លែងផ្សេង ហើយត្រូវរក្សាសម្លៀកបំពាក់នោះឲ្យមានក្លិនក្រអូបបែបស្រាលៗផងទើបពេលគាត់យកពាក់មានអារម្មណ៍ល្អ និងមានក្លិនក្រអូបពេលនៅជិតអ្នកដទៃ»។

អ្នកស្រីបន្ថែមថា«ប្តីតែងតែពោលសរសើរនិងអរគុណខ្ញុំមុនពេលចេញទៅធ្វើការស្ទើរាល់ថ្ងៃ។ ទង្វើរនេះធ្វើឲ្យខ្ញុំសប្បាយចិត្តនិងមានអារម្មណ៍កក់ក្តៅជាខ្លាំងពីស្វាមី ។ ចឹងហើយទើបខ្ញុំតែងតែយកចិត្តទុកដាក់ក្នុងការបំពេញកិច្ចការផ្ទះសំបែង ម្ហូបអាហារ និង រឿងសម្លៀកបំពាក់ប្តីតែម្តង»។

លោក ព្រុំ វិបុល វ័យ ៣៧ ឆ្នាំជាមេការសំណង់នៅទីក្រុងភ្នំពេញបានឲ្យដឹងថាសម័យនេះទំនើបមានម៉ាស៊ីនបោកខោអាវស្រាប់ ហើយមានហាងបោកអ៊ុតស្ទើរគ្រប់ទីកន្លែង។ វាជាភាពងាយស្រួលម្យ៉ាង គ្រាន់តែត្រូវចំណាយលុយបន្តិច។ ចំពោះលោកយូរៗម្តង យកខោអាវទៅឲ្យគេបោកអ៊ុតព្រោះប្រពន្ធរវល់។

លោកវិបុលនិយាយទៀតថា ក្នុងគ្រួសារលោក គឺជួយគ្នាទៅវិញទៅមកក្នុងការបោកសម្អាតសម្លៀកបំពាក់ប្រចាំថ្ងៃនេះ ព្រោះម្នាក់ៗសុទ្ធតែរវល់ដូចគ្នា គ្រាន់តែការរៀបចំទុកដាក់លើកិច្ចការនេះ ប្រពន្ធរ៉ាប់រងច្រើនជាង។

លោកបានបន្តទៀតថា៖ «ខ្ញុំតែងតែមានអារម្មណ៍មោទនភាពនិងកក់ក្តៅ នៅពេលឃើញប្រពន្ធយកចិត្តទុកដាក់រៀបចំរបស់ប្រើប្រាស់ប្តី ឬខោអាវជាដើម ព្រោះបញ្ជាក់ថានាងយកចិត្តទុកដាក់ចំពោះយើង ហើយតែងតែខ្វាយខ្វល់អំពីភាពសមរម្យរបស់ប្តីជានិច្ច»។

លោកវិបុលបន្តថា លោកទទួលស្គាល់ថាប្រពន្ធមិនមែនជាអ្នកបម្រើក្នុងផ្ទះ ដែលត្រូវធ្វើកិច្ចការគ្រប់យ៉ាងនោះទេ។ តែបើប្រពន្ធមិនចាប់អារម្មណ៍អំពីកិច្ចការទាំងអស់នេះ ក៏វាមិនមែនជារឿងល្អប្រសើរដែរ ទោះបីស្ថិតក្នុងសម័យកាលអីក៏ដោយ៕

# សាធារណជនកំពុងតែព្រួយបារម្ភអំពីការរីករាលដាលអូទីហ្សឹមនៅកម្ពុជា

បណ្ដាយុវជន និងយុវនារី ដែលកំពុងតែមានគម្រោងចាប់ដៃគ្នាកសាងគ្រួសារ និង គូស្រករថ្មោងថ្មីមួយចំនួន ដែលទើបតែបានចាប់ដៃគ្នាកសាងគ្រួសារ ក៏ដូចជាសាធារណជនទូទៅ នៅកម្ពុជាកំពុងតែមានការព្រួយបារម្ភអំពីជំងឺថ្មីៗប្លែកៗ ដែលអាចនឹងកើតមានចំពោះបុត្រធីតារបស់ពួកគេនៅពេលអនាគតម្យ៉ាងដែលគេហៅថា អូទីហ្សឹម( Autism )។

*ដោយ៖ អរិយបុត្រ*

ពួកគេមួយចំនួនបានដឹង និងស្គាល់ជំងឺនេះ ហើយបានចូលរួមសម្ដែងយោបល់របស់ពួកគេខុសៗគ្នា អំពីជំងឺថ្មីនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានអ្នកដែលនៅមិនទាន់បានដឹងអំពីជំងឺ ថ្មីនេះជាទូទៅនៅឡើយទេ ជាពិសេស គឺគ្រួសារនៅជនបទ និង អ្នកដែលស្ថិតនៅក្នុង មជ្ឈដ្ឋានដែលមិនសូវយកចិត្តទុកដាក់ឬក៏តាមដានព័ត៌មាន។

ជំងឺដែលមនុស្សកំពុងតែប្រឈមមុខនាពេលបច្ចុប្បន្ននេះគឺថ្មីៗហើយក៏ប្លែកៗផងដែរ ហើយនៅក្នុងចំណោមជំងឺថ្មីៗហើយប្លែកទាំងនោះ ជំងឺដែលគួរឲ្យចាប់អារម្មណ៍ ហើយដែលពលរដ្ឋកម្ពុជា មួយចំនួនខ្វះការយល់ដឹងនោះគឺអូទីហ្សឹម ជំងឺពងបែកដៃ ជើង និងមាត់... ។ល។ នៅក្នុងចំណោមជំងឺទាំងនេះ មានជំងឺខ្លះគឺវាបានមកដល់កម្ពុជា ហើយជំងឺខ្លះក៏នៅមិនទាន់មានព័ត៌មានមកកម្ពុជា នៅឡើយទេ ដោយឡែកជំងឺអូទីហ្សឹម ត្រូវបានគេដឹងថា វាក៏មកដល់កម្ពុជាយូរហើយផងដែរ ហើយបើទោះបីជាជំងឺនេះ មិនបានសម្លាប់ជីវិតកុមារយើងដោយផ្ទាល់ក៏ពិតមែន ក៏វាជាប្រភេទជំងឺដែលកំពុងតែចូលរួមសម្លាប់ជីវិតកុមារ និង បំផ្លាញជីវិតកុមារកម្ពុជាដោយ ប្រយោល ប្រសិនបើកុមារមិនអាចព្យាបាលបានទាន់ពេលវេលា។

លោក សេក បុណ្ណា អាយុ ២៨ឆ្នាំ ដែលគ្រោងនឹងរៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំក្រោយ បានចូលរួមចែករំលែកការព្រួយបារម្ភរបស់ខ្លួនថា ក្រៅពីជំងឺសង្គមដែលកើតមានមកលើមនុស្សពេញវ័យ ហើយនឹងឆ្លងទៅកុមារហើយនោះ ក៏នៅមានជំងឺថ្មីៗជាច្រើនដែលអាចនឹងធ្វើឲ្យ កុមាររងគ្រោះ។

លោក បុណ្ណា បានបន្តថា ចាប់តាំងពីលោកបានភ្ជាប់ពាក្យ ហើយគ្រោងរៀបការមក លោកតែងតែចាប់អារម្មណ៍មែនទែននឹងព័ត៌មានសុខភាព ដោយរួមទាំងសុខភាពខាងផ្លូវភេទ ក៏ដូចជាផ្លូវចិត្ត និង ជាពិសេសគឺសុខភាពមាតាទារក និងកុមារ។

លោកបានបញ្ជាក់ថា៖ «កាលនៅមិនទាន់មានគំនិតរៀបការ មិនចេះខ្វល់ទេ កើតស្អីក៏កើតទៅ ប៉ុន្តែពេលនេះមិនបានទេ ពីព្រោះបើធ្វេសប្រហែស មិនមែនគ្រោះថ្នាក់តែយើងខ្លួនមួយទេ គឺគ្រួសារទាំងមូល»។

លោកបានរៀបរាប់ថា ក្រៅពីខ្លួនឯង លោកកំពុងតែយកចិត្តទុកដាក់នឹងជំងឺផ្លូវចិត្តម្យ៉ាង ដែលមានវត្តមាននៅកម្ពុជា គឺអូទីហ្សឹម។ ហើយត្រូវបានគេចែករំលែក និងជជែកគ្នាក៏ច្រើនផងដែរ។

លោក បុណ្ណា ថា៖ «មិនបានទេ ជំងឺនេះ ‘ អូទីហ្សឹម ’ វាគ្រោះថ្នាក់ណាស់សម្រាប់ក្មេង។ ខ្ញុំតាមដានជាបន្តបន្ទាប់»។

ដោយឡែកកញ្ញា ទេព ផល្លីកា ជាយុវតីដែលកំពុងតែគិតគូរអំពីចំណងគ្រួសារមួយរូបដែរនោះ បានបញ្ចេញនូវទស្សនៈ និងការយល់ដឹងរបស់កញ្ញាថា វាពិតជាព័ត៌មានដ៏រន្ធត់នៅពេលដែលឃើញគ្រួសារ ឬអាណាព្យាបាល ចែករំលែកនូវព័ត៌មានអំពីជំងឺកុមារ ប៉ុន្តែកញ្ញា តែងតែយកចិត្តទុកដាក់មិនដែលរំលងឡើយ។

ផល្លីកា បានថ្លែងបញ្ជាក់ថា៖ «ឲ្យតែឮឬ បានឃើញព័ត៌មានអំពីជំងឺ ជាពិសេសគឺជំងឺកុមារ ខ្ញុំមិនដែលរំលងទេ។ បើសិនមិនបានមើល ឬអាន ក៏កូពីរ ( ថតចម្លង ) ទុកមើលថ្ងៃក្រោយដែរ»។

កញ្ញា បានបន្តទៀតថា ដូចជាប៉ុន្មានថ្ងៃមុន ព័ត៌មានដែលស្ត្រីជាម្ដាយកុមារមួយរូប យំ និងរៀបរាប់ចែករំលែកការឈឺចាប់តាមបណ្ដាញព័ត៌មានសង្គម ពោលគឺហ្វេសប៊ុក គឺពិតជាព័ត៌មានដ៏រន្ធត់ ដែលយើងត្រូវតែយកចិត្តទុកដាក់។

កញ្ញាបានរៀបរាប់ថា៖ «អរគុណអ្នកដែលបានចែករំលែក នោះគឺជាបទពិសោធន៍ដ៏ល្អ ដែលមិនអាចមើលរំលងបាន»។

កញ្ញា បានបន្តទៀតថា នៅក្នុងជំងឺថ្មីៗប្លែកៗ ដែលកញ្ញាតែងតែចាប់អារម្មណ៍ គឺប្រភេទជំងឺផ្លូវចិត្តម្យ៉ាង ដែលគេហៅថា អូទីហ្សឹម។

តាមការចែករំលែកព័ត៌មាន ផល្លីកា បានថ្លែងថា ជំងឺនេះ ( អូទីហ្សឹម ) ពិតជាគ្រោះថ្នាក់មែនទែនសម្រាប់កុមារ ដោយរៀបរាប់បញ្ជាក់ថា៖ «តាមខ្ញុំតាមដានព័ត៌មាន តាមហ្វេសប៊ុក និងតាមវិទ្យុផ្សេងៗកន្លងមក ខ្ញុំយល់ថា ក្មេងៗដែលកើតជំងឺនេះ គឺគ្នាមិនមានការឈឺចាប់ មិនកើតទុក្ខអ្វីទាំងអស់ ប៉ុន្តែសម្រាប់គ្រួសារ គឺចប់តែម្ដង។ ទាំងខ្ញុំ ទាំងគេ បើសិនជា ឃើញ កូនខ្លួនឯងកើតបែបនេះ តើឈឺចាប់ប៉ុណ្ណា »។

ផល្លីកា បានថ្លែងថា ដោយសារតែបែបនេះ កញ្ញា តែងតែយកចិត្តទុកដាក់មែនទែន និងព័ត៌មានទាក់ទងនឹងគ្រួសារ និងកុមារ ក៏ដូចជា ព័ត៌មានអំពីសុខភាព។

ទាក់ទិន និងបញ្ហាចម្ងល់សុខភាព លោកស្រី អៀ វឌ្ឍនា ជាមាតារបស់កុមារានិងកុមារីចំនួន ៤រូប នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានបង្ហាញចម្ងល់ នៅពេលដែលអ្នកនាំសារសាកសួរលោកស្រី អំពីជំងឺ អូទីហ្សឹម។

លោកស្រី បានសួរត្រឡប់មកវិញថា៖ «ស្អីគេ អូទីហ្សឹម! ៗ តើវាជាស្អី ខ្ញុំដូចជាមិនដែលបានដឹង»។ លោកស្រីបានឲ្យដឹងថា កន្លងមក លោកស្រីស្គាល់ត្រឹមតែគ្រុនឈាម គ្រុនក្ដៅ គ្រុនចាញ់ រាគ ក្ដៅខ្លួន គ្រុនពោះវៀន... ប៉ុណ្ណោះ។

លោក ទេព កុសល ដែលជាអ្នកប្រកបរបររត់ឡាំប្រឺតា មួយរូប ក៏មិនបានដឹង និងស្គាល់អូទីហ្សឹម នេះផងដែរ។ ដោយលោកបានអះអាងថា មិនបានដឹងទេ ដោយមួយថ្ងៃៗ មិនដែលមានពេល តាមដានព័ត៌មាន។

ទាក់ទិននឹងការព្រួយបារម្ភខាងលើ អ្នកស្រី គីម ផល្លា អ្នកសម្របសម្រួលកម្មវិធីអប់រំពិសេសនៅ មណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈជនមានពិការភាពបន្ទាយព្រាប ដែលកំពុងតែបណ្ដុះបណ្ដាលយុវជនអូទីហ្សឹមនេះ ចំនួន ១២រូបរួមជាមួយនឹង យុវជនដែលមានពិការភាពទាំងរាយកាយ និងកម្សោយបញ្ញាស្មារតីផ្សេងទៀត ពីអាយុ ១៨ ដល់ ៣៥ឆ្នាំ បានឲ្យដឹងថា កុមារ និងមនុស្សអូទីហ្សឹមនេះមិនមែនជាអ្នកជំងឺទេ។ ហើយអូទីហ្សឹមមិនមែនជារឿងថ្មីនៅកម្ពុជាឡើយ គឺវាមានវត្តមាននៅកម្ពុជាយូរដែរហើយ គ្រាន់តែយើងមិនសូវចាប់អារម្មណ៍។

លោកស្រីបានឲ្យដឹងថា តាមទ្រឹស្ដីកុមារអូទីហ្សឹមនេះជាទូទៅមានបញ្ហាសំខាន់៣ នៅក្នុងការអភិវឌ្ឍរួមមាន ការទំនាក់ទំនងសង្គម ជំនាញភាសា និងអាកប្បកិរិយា។

លោកស្រីបានពន្យល់លំអិតថា ចំពោះកុមារដែលមានបញ្ហាប្រភេទនេះ មានលក្ខណៈដូចខាងក្រោម

លើជំនាញសង្គម គឺពួកគេមិនអាចឆ្លើយតបឈ្មោះពួកគេចំពោះមុខយើង ពួកគេខ្សោយទំនាក់ទំនងតាមខ្សែរភ្នែក អត់ចូលចិត្តលេងជាក្រុម មិនយល់ពីអារម្មណ៍ពេលខឹង ស្រែក សើចយំ ពួកគេមិនដឹងពីគ្រោះថ្នាក់ចំពោះ ខ្លួនគេឡើយ ហើយគឺពួកគេមិនយល់ពីអ្វីដែលយើងនិយាយជាមួយជាដើម។

លោកស្រីបានបន្តទៀតថា ចំពោះចំណុចជំនាញភាសាវិញ គឺថា ការទំនាក់ទំនងតាមរយៈការនិយាយ និងមិននិយាយរបស់ពួកគេគឺមិនមានទាល់តែសោះ ឬមានកម្រិតដែលខ្វះនូវមធ្យោបាយក្នុងការសន្ទនា។ ពួកគេមិនយល់កាយវិការ គំនិតអ្នកដទៃ និងបកប្រែលើសពាក្យដែលនិយាយ។ ពួកគេមិនមានរបៀបទំនាក់ទំនង ពួកគេច្រើននិយាយប៉ប៉ាចប៉បោច ពួកគេមានភាពមិនប្រក្រតីក្នុងការ ទំនាក់ទំនង ពួកគេមិនមានភាពស្រមើស្រមៃនូវសកម្មភាពលេងសកម្មភាពសម្ដែងរបស់មនុស្ស និងភាពច្នៃប្រឌិត ឬមួយពួកគេចូលចិត្តនិយាយដដែលៗ ហើយប្រយោគនោះគឺជាប្រយោគត្រង់ ...។ល។

ចំពោះចំណុច អកប្បកិរិយាវិញ លោកស្រី គីម ផល្លា មានប្រសាសន៍ថា កុមារអូទីហ្សឹម គឺពួកគេរមែងបង្កើតទម្លាប់ជាក់លាក់មួយ ពួកគេធ្វើចលនាជានិច្ចពោលគឺរពឹស ហើយពេលដែលគាត់ឈប់លេង ឬពេញចិត្តវត្ថុណាមួយ គឺគាត់គ្រវាត់វត្ថុនោះចោលភ្លាមៗ។ កុមារពិបាកនៅក្នុងការផ្លាស់ប្ដូរទម្លាប់ ពោលគឺថា តែគាត់ទៅរៀនម៉ោង ៧ គឺ ៧ ហើយ ខុសគ្នាតែ ៥នាទីក៏គាត់មិនសុខចិត្តដែរ ហើយចេញពីរៀនវិញក៏ដូចគ្នាខុសតែ ៥នាទី ក៏មានបញ្ហាដែរ ។ លោកស្រី បានបន្តទៀតថា សូម្បីតែផ្លូវដែលយើងជូនគាត់ទៅសាលាគឺទៅផ្លូវណា គឺផ្លូវនោះ តែខុសគឺគាត់មិនសុខចិត្តតែម្ដង។

នៅលើចំណុចដដែលនេះ លោកស្រី គីម ផល្លា បានមានប្រសាសន៍បន្តទៀតថា កុមារខ្លះគឺមានប្រតិកម្មរាងកាយខ្លាំង។ ពេលខ្លះ យើងប៉ះគាត់ឬស្ទាបគាត់តែបន្តិច គឺគាត់ស្រែកតែម្ដង រីឯកុមារខ្លះ គឺអត់មានអារម្មណ៍ឈឺចាប់ទៅវិញ ខ្លះប៉ះពាល់សម្លេង ខ្លះទៀតអត់ចេះគ្រប់គ្រងខ្លួនឯង វាយគេ វាយឯង ខ្លះប៉ះពន្លឺមិនបាន ខ្លះចូលចិត្តពន្លឺខ្លាំង ក្មេងខ្លះបង្កើតសម្លេងដោយខ្លួនឯង។

លោកស្រីបានបន្តថា ចំពោះមូលហេតុដែលបណ្ដាលឲ្យមានមនុស្សអូទីហ្សឹម គឺមានការសន្និដ្ឋានផ្សេងៗគ្នា ដោយទ្រឹស្ដីខ្លះគេថាមកពីបរិស្ថាន ហើយទ្រឹស្ដីខ្លះគេថាមកពីហ្សែន ហើយបានសង្កត់ធ្ងន់ថា មនុស្សអូទីហ្សឹមនេះមិនមែនបណ្ដាលមកពីបច្ចេកទេស ឬឧបករណ៍អេឡិចត្រូនិចធ្វើឲ្យកើតអាការៈបែបនេះទេ។

លោកស្រីថា៖ «អូទីហ្សឹម មិនមែនកើតដោយសារតែឧបករណ៍បច្ចេកវិទ្យាទេ។ មិនមែនបច្ចេកទេសធ្វើឲ្យកើតអាការៈនេះទេ តែឧបករណ៍បច្ចេកទេស ដូចជា ទូរសព្ទដៃអ៊ីហ្វឹង វាអាចបណ្ដាល ឲ្យកុមារកាន់តែធ្ងន់ធ្ងរ ប្រសិនបើអាណាព្យាបាលខ្វះការយកចិត្តទុកដាក់»។

លោកស្រី គីម ផល្លា ក៏បានសំណូមពរឲ្យអាណាព្យាបាល ចាប់ផ្ដើមសង្កេត និងសម្គាល់បុត្រធិតារបស់ខ្លួន ចាប់ពី អាយុ ១ឆ្នាំកន្លះឡើងទៅ ហើយបើសង្កេតឃើញ បុត្រធីតារបស់ខ្លួនមានលក្ខណៈ ដូចជារៀបរាប់ខាងលើទាំងបីចំណុចធំៗ សូមប្រញាប់ស្វែងរក សេវាពិគ្រោះ យោបល់ ដែលពេលនេះ គឺមានទូលំទូលាយជាងមុន។

លោកស្រីបានបញ្ជាក់ថា៖ «ចំពោះអូទីហ្សឹម មិនត្រូវការព្យាបាលទេ ប៉ុន្តែមានការព្យាបាលដោយធ្វើការកាត់បន្ថយអាកប្បកិរិយាដែលអាចធ្វើឲ្យប្រសើរឡើងនូវរាគសញ្ញារបស់កុមារ អូទីហ្សឹម ជួយដល់សមត្ថភាពរៀន និងគុណភាពនៃជីវិតរបស់ពួកគេ»៕



*កុមារអូទីហ្សឹមនឹងកាន់តែធ្ងន់ធ្ងរ ប្រសិនបើអាណាព្យាបាលខ្វះការយកចិត្តទុកដាក់។ រូបភាព៖ សុធីរិទ្ធិ*



*កុមារអូទីហ្សឹមត្រូវការព្យាបាលជាពិសេសស និងការយកចិត្តទុកដាក់។ រូបភាព៖ សុធីរិទ្ធិ*



*កុមារអូទីហ្សឹម ចូលរួមសកម្មភាពកីឡារបស់អង្គការករុណាបាត់ដំបង។ រូបភាព៖ ករុណាបាត់ដំបង*



*កុមារអូទីហ្សឹម ស្ថិតនៅក្នុងមណ្ឌលសុខសាន្តបានទទួលការព្យាបាលពីគ្រូពេទ្យជំនាញ។ រូបភាព៖ មណ្ឌលសុខសាន្ត*

# ស្ត្រីជាម្តាយគួរកុំ ! ទម្លាប់តាមចិត្តកូនតូច

ដោយ៖ រឿន ស្រីម៉ាច

«កុមារតូច» ត្រូវការអប់រំប្រៀនប្រដៅពីឪពុកម្តាយ ឬអាណាព្យាបាលជាចាំបាច់ ដើម្បីពត់តម្រង់ពួកគេបានក្លាយជាមនុស្សល្អ គឺត្រូវប្រតិបត្តិពីក្មេងទៅ ចៀសវាងពេលធំឡើងពិបាកស្តីប្រដៅ។ សព្វថ្ងៃនេះដោយសារតែក្តីស្រលាញ់របស់ឪពុកម្តាយមួយចំនួនខ្លាំងចំពោះកូនតូចៗធ្វើឱ្យមានការទម្លាប់តាមចិត្តកូន ឬការតាមយកចិត្តកូនស្ទើរគ្រប់កាលៈទេសៈ ចំណុចនេះធ្វើឱ្យក្មេងជាទំពាំងមួយដើមនៅពេលធំឡើងនឹងដុះជាដើមឫស្សីវៀច ឬកោង ហើយទីបំផុតផលលំបាកត្រូវពិបាកដល់ខ្លួនឯង និង សង្គមថែមទៀត។

អ្នកស្រី តែង សុគន្ធ វ័យ ៣១ឆ្នាំ ជាបុគ្គលិកបម្រើក្នុងក្រុមហ៊ុនមួយកន្លែងក្នុងទីក្រុងភ្នំពេញបានឱ្យដឹងថា៖ «រហូតដល់ពេលនេះនៅស្តាយក្រោយមិនទាន់បាត់ចំពោះទង្វើខុសឆ្គងទៅលើកូនដោយក្តីស្រលាញ់គឺទាំងពីរនាក់ប្តីប្រពន្ធតែងតែតាមចិត្តកូនគ្រប់ពេលវេលា ព្រោះមិនចង់ឱ្យគេមិនសប្បាយចិត្តឬយំនៅពេលដែលទារចង់ទិញអ្វីមួយជាដើម ហើយរហូតដល់ពេលនេះ កូនអាយុ៨ឆ្នាំហើយ នៅតែមានទម្លាប់រឹងរូសចង់បានអ្វីគឺត្រូវតែបានតាមចិត្តរហូត»។

ស្ត្រីរូបនេះបន្ថែមថា ជួនកាលគាត់បានចំណាយលុយទៅលើរបស់ក្មេងលេងច្រើន ទោះបីជាកូនមិនបានសុំក៏ដោយ ព្រោះគិតថាវាមានតម្លៃមិនសូវជាថ្លៃ ហើយចង់ឱ្យកូនសប្បាយចិត្តពេលឃើញរបស់ទាំងនោះ ដោយមិនបានគិតថាទង្វើបែបនេះធ្វើឱ្យកូនបានចិត្ត ឬដឹងចិត្តមិនរអារក្នុងការស្តីប្រដៅនៅថ្ងៃក្រោយព្រោះគេដឹងថាឪពុកម្តាយស្រលាញ់គេខ្លាំង។

តាមរយៈបទពិសោធន៍៨ឆ្នាំចាប់ពីពេលកូនកើតរហូតដល់ថ្ងៃនេះ ការចិញ្ចឹមកូនអ្នកស្រី សុគន្ធ ឲ្យដឹងថា ការស្រលាញ់និងអប់រំកូនគឺមិនត្រូវតាមចិត្តរបស់គេពេកទេ ព្រោះនឹងធ្វើឱ្យពួកគេក្លាយជាមនុស្សមិនល្អនៅពេលអនាគត។ អ្នកស្រីបញ្ជាក់ថា៖ «បើស្រលាញ់កូនគួរកុំបណ្តោយតាមចិត្តកូន ឬទុកគេដូចស្តេចក្នុងផ្ទះទង្វើនេះធ្វើឱ្យមានភាពស្តាយក្រោយដូចខ្ញុំ»។

កំពុងអង្គុយបញ្ចុកអាហារកូនក្នុងហាងអាហារបទេសមួយកន្លែងម្តុំមុខវាំង អ្នកស្រី ជិន ដារតនា វ័យ៤២ឆ្នាំ ជាស្ត្រីមេផ្ទះ ឲ្យដឹងថា កម្រិតជីវភាពរបស់គ្រួសារអ្នកស្រី គឺធូរធារមិនសូវខ្វល់ខ្វាយពីការចំណាយប៉ុន្មានទេ។ អ្នកស្រីបន្ថែមថា៖ «ប្តីនិងអ្នកជិតខាងតែងតែប្រាប់ថាកុំបណ្តោយតាមចិត្តកូនធ្វើឱ្យគេមិនស្តាប់បង្គាប់នៅថ្ងៃក្រោយ តែមិនដែលស្តាប់គេព្រោះគិតថា គេក្មេងមិនដឹងអីទេ។ តែរហូតពេលនេះកូនខ្ញុំមានអាយុ៣ឆ្នាំ និង៥ឆ្នាំហើយ គឺនិយាយមិនបាន គេចង់បានអីត្រូវតែបាន ហើយមិនចូលចិត្តញាំអាហារនៅផ្ទះទេ ទាល់តែនាំទៅហាងបានគេញាំ។ នេះគឺខុសមកពីខ្ញុំដែលទម្រើសតាមចិត្តកូនតាំងពីដើមរហូតមក ចំណុចនេះនាំឱ្យខ្ញុំព្រួយបារម្ភនៅថ្ងៃខាងមុខកូននៅតែបន្តបែបនេះទៀតឬយ៉ាងណា?»។

ឯអ្នកស្រី ញ៉ឹម ចាន់ថន វ័យ ២៨ឆ្នាំ មានរបរជាអ្នកធ្វើក្រចកចល័តនៅផ្សារសុវណ្ណាបានឱ្យដឹងថា «ដោយសារតែខ្ញុំមានជីវភាពក្រីក្រចឹង ការអប់រំកូនរបស់ខ្ញុំ បង្រៀនឱ្យកូនចេះអត់ធុន ស៊ូទ្រាំ ដោយការនិយាយពន្យល់សម្តីល្អៗទៅកាន់កូនតូចដែលមានអាយុទើបតែ២ឆ្នាំ ព្រោះគេចេះស្តាប់ចេះនិយាយអីចឹងកូនយល់ថាម៉ាកនិយាយអំពីអ្វី»។

អ្នកស្រី ចាន់ថន បន្តថា កូនរបស់គាត់មានទម្លាប់ដូចមនុស្សធំដឹងក្តី ដោយចេះស្តាប់ពាក្យទូន្មាន ការហាមប្រាមនានា មានរបៀប និងទម្លាប់ល្អ និងមានសុជីវធម៌ជាដើម។

អ្នកស្រីបន្ថែមថា៖«ខ្ញុំមិនបានរៀនច្រើននៅសាលា តែខ្ញុំមើលឃើញពីសង្គមខាងក្រៅច្រើន ជាពិសេសការតាមចិត្តកូនច្រើន ដោយមិនបង្រៀនគេឱ្យមានរបៀបឬវិន័យត្រឹមត្រូវទេ នឹងណែនាំឱ្យកូនទៅជាក្មេងខូចបាន។ ហេតុនេះបើទោះបីជារវល់នឹងការងាររកប្រាក់យ៉ាងណាក្តី ខ្ញុំតែងតែចំណាយពេលនិយាយបង្រៀន និងលេងជាមួយកូន ពេលគេធ្វើខុសឱ្យគេចេះទទួលកំហុស ពេលគេធ្វើត្រូវគឺសសើរ គឺធ្វើយ៉ាងណាកុំឱ្យកូនដឹងចិត្ត»។

តាមការស្រាវជ្រាវរបស់អ្នកចិត្តវិទ្យារបស់សកលវិទ្យាល័យអាមេរិកជាច្រើន ដែលគេហទំព័រកោះថ្មីចុះផ្សាយបានឲ្យដឹងថា ការធ្វើតាមចិត្តកូនពេលគេនៅក្មេងរហូតដល់ធំពេញវ័យ កុមារទាំងនោះមានអត្តចរិតមិនសូវមានការអត់ធ្មត់ និងចង់បានអ្វីគឺចង់បានភ្លាមៗ។

លោកបណ្ឌិត ឌែន ខាយឡូន អ្នកចិត្តវិទ្យាប្រចាំសាកលវិទ្យាល័យហាវ៉ាត បានឱ្យដឹងថា ទង្វើនេះ គឺកើតឡើងដោយសារឪពុកម្តាយតែងធ្វើតាមកូនជានិច្ច។ ការធ្វើបែបនេះមិនត្រឹមតែធ្វើឱ្យកូនខូចទេ ប៉ុន្តែវាបង្កការខ្វះខ្វាយថវិកាដែលចំណាយខុសខ្ទង់។ លោកបាននិយាយពីរឿងនេះថា មិនមានអ្វីប្លែកទេដែលក្មេងអាយុ ៤ ឆ្នាំ ស្រែកយំទារទិញស្បែកជើងថ្មី និងទារធ្វើខួបកំណើតជាដើម។

ចំណែកលោកសាស្ត្រាចារ្យ ភីធើ គ្រេ អ្នកស្រាវជ្រាវផ្នែកចិត្តវិទ្យានៅរដ្ឋប៊ុស្តុន ខលជេន និង ជាអ្នកនិពន្ធសៀវភៅ Free To Learn បានពន្យល់ថា ក្មេងសម័យនេះថយចុះភាពអត់ធ្មត់ និង ទន់ភ្លន់ ប៉ុន្តែបែរជាមានក្តីកង្វល់ ទុក្ខសោក និង ភ្លើតភ្លើន។ ទាំងនេះកើតឡើងដោយសារពួកគេកើតមក ស្របជាមួយនឹងសម័យទំនើប៕



*នេះគឺខុសមកពីខ្ញុំដែលទម្រើសតាមចិត្តកូនតាំងពីដើមរហូតមក ចំណុចនេះនាំឱ្យខ្ញុំព្រួយបារម្ភនៅថ្ងៃខាងមុខកូននៅតែបន្តបែបនេះទៀតឬយ៉ាងណា?*





# តំបន់ជ្រោយមួយនៅអូស្ត្រាលី មានខ្យល់បរិសុទ្ធបំផុតនៅលើលោក

ដោយ៖ ផាត សំភី



*ក្រៅពីទីតាំងស្តង់ដារសម្រាប់អ្នកវិទ្យាសាស្ត្រស្រាវជ្រាវ តាស្មានី គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរដ៏មានសក្តានុពល។ រូបភាព៖ Getting Image*

ជាទូទៅ នៅតំបន់អាស៊ីប៉ាស៊ីហ្វិកតែងតែមានខ្យល់ដែលធ្វើឲ្យថប់ដង្ហើមក្អក ហៀរសំបោរ។ ហើយនៅក្នុងរដូវនេះ ជាទូទៅអនុគ្រោះដល់ការពុលរបស់ខ្យល់។ ប៉ុន្តែនៅជ្រុងម្ខាងទៀតនៃតំបន់នេះ នៅដាច់ឆ្ងាយពីគេ នៅលើកោះអូស្ត្រាលី តាស្មានី គឺជាករណីលើកលែង។

គេបានធ្វើការបញ្ជាក់ និងត្រូវបានប្រើប្រាស់ជាសេចក្តីយោងជាលក្ខណៈអន្តរជាតិ សម្រាប់ខ្យល់ដែលបរិសុទ្ធ។ នៅលើជ្រោយ កាបហ្គ្រីម ក៏មានផ្តល់នូវទស្សនីយភាពដ៏អស្ចារ្យ ជាមួយនឹងវាលស្មៅដែលលាតសន្ធឹងដ៏ធំធេងរបស់ខ្លួន និងទឹកដែលឆ្លុះពណ៌ដូចត្រីស្តាលើនៃសមុទ្រអូស្ត្រាលី។ ទីកន្លែងនេះគឺអស្ចារ្យណាស់។ វាក៏ជាកន្លែងស្តង់ដារមួយសម្រាប់អ្នកវិទ្យាសាស្ត្រផងដែរ។

វាគឺជាកន្លែងអស្ចារ្យសម្រាប់វាស់ជាតិពុលនៅក្នុងខ្យល់។ ចាប់តាំងពីឆ្នាំ ១៩៧៦ តំបន់នៃផែនដីព្រៃ និងសម្បូរខ្យល់ គេបានសង់ស្ថានីយ៍វាស់កម្រិតជាតិពុល នៅលើជ្រោយកាបហ្គ្រីម។ នេះគឺជាហេដ្ឋារចនាសម្ពន្ធសាធារណៈរបស់រដ្ឋអូស្ត្រាលី ដែលមួយផ្នែកទទួលការងារដើម្បីអាចយកខ្យល់ទៅច្រកក្នុងដបដើម្បីពិសោធន៍ និងវាស់ជាតិពុល។

លោកសំ គ្លីឡេន មន្ត្រីទទួលខុសត្រូវនៅលើស្ថានីយ៍ដែលបន្តុបនៅលើច្រាំងចោត ពន្យល់ទៅកាន់ទីភ្នាក់ងារសារព័ត៌មានបារាំង ថា «ការងាររបស់យើងគឺស្វែងរកខ្យល់ដែលបរិសុទ្ធបំផុតនៅលើពិភពលោក និងដើម្បីវាស់អំពីកម្រិតជាតិបំពុលរបស់វា»។

បើគេឆ្ពោះទៅកាន់ភាគខាងលិចនេះគឺជាតំបន់របស់ផែនដីដែលនៅជិតបំផុតទៅនឹងប្រទេសអាហ្សង់ទីន។ ហើយនៅក្នុងទិសដៅទៅកាន់ភាគខាងត្បូង គឺគ្មានអ្វីក្រៅពីទ្វីបអង់តាកទិចនោះទេ។

ការស្ថិតនៅដាច់ដោយឡែកនៃស្ថានីយ បានធ្វើឲ្យវាក្លាយជាកន្លែងល្អឥតខ្ចោះដើម្បីប្រមូលនូវអ្វីដែលមនុស្សជាច្រើន ហៅថា ខ្យល់ដែលបរិសុទ្ធបំផុតនៅលើផែនដី ដែលចៀសផុតពីឧស្ម័នដែលបញ្ចេញពីរោងចក្រ និងផ្សេងពីការដាំដំណាំកៅស៊ូ..ភស្តុតាងត្រូវបានបង្ហាញឡើងនៅក្នុងខ្យល់។

នៅខណៈដែលទីក្រុងនានាទទួលរងការបំពុលបំផុតនៃពិភពលោក មានការលំបាកនឹងទាក់ទាញអ្នកមានទេពកោសល្យ ឬតែងបង្កឲ្យមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ ប្រជាជននៃជ្រោយកាបហ្គ្រីម ដែលនៅដាច់ឆ្ងាយពីគេមានសុខភាពប្រសើរ។ ពួកគេតែងធ្វើឲ្យបរិស្ថានរបស់ពួកគេ ស្ទើរតែជិតដល់កម្រិត ដែលគ្មានរងផលប៉ះពាល់មានខ្យល់ជាឧទាហរណ៍។

តួយ៉ាងដើម្បីលក់សាច់គោនៅក្នុងតំបន់ គេត្រូវបញ្ជាក់អំពីការសិក្សាវិទ្យាសាស្ត្រអំពីគុណភាពនៃខ្យល់។ ហើយចំនួនដែលកាន់តែកើនឡើងនៃស្ថានីយអគ្គីសនីដែលដើរដោយខ្យល់ និងភ្ញៀវទេសចរណ៍ដែលមកស្រូបខ្យល់អាកាសបរិសុទ្ធ ក៏បានបង្ហាញអំពីកិត្តិនាមនៃកន្លែងបរិសុទ្ធដែលកាន់តែធ្វើឲ្យគេស្គាល់បន្តិចម្តងៗ។

លោកម៉ាក ប៊ុកប៊ី អ្នកដាំដុះអាស្រ័យលើទឹកភ្លៀងនៅក្រុមហ៊ុនទឹកនៃជ្រោយកាបហ្គ្រីម បានប្រមូល និងធ្វើពាណិជ្ជកម្មលើទឹកដែលធ្លាក់មកពីមេឃា ដែលបរិសុទ្ធបំផុតនៅលើផែនដី”។ លោកបានពន្យល់ថា នៅលើពិភពលោក ភាគច្រើននៃទឹកគឺជាទឹកដែលមានប្រភពចេញពីភ្នំ”។

លោកម៉ាក ប៊ុកប៊ី និយាយនៅពីមុខប្រព័ន្ធអាងបម្រុងទឹក និងមានទ្វារទឹករបស់គាត់ដែលស្ថិតនៅលើផ្ទៃដីដែលមានទំហំពាក់កណ្តាលទីលានបាល់ទាត់ ហើយរាងនៅឆ្ងាយពីឆ្នេរបន្តិច។លោកម៉ាក ប៊ុកប៊ី បន្តថា ៖ “គេអាស្រ័យទៅលើទឹកភ្លៀងនេះដែលមកពីមហាសមុទ្រខាងត្បូង។”

បើតាមលោក ទឹករបស់លោកដែលមានរសជាតិគួរឲ្យកត់សម្គាល់ គឺមានផ្ទុកតែទឹកក្នុងរូបមន្ត H2O (អាតូមអ៊ីដ្រូសែនពីរ និងអាតូមអុកស៊ីសែនមួយ) និងស្នាមដាននៃអំបិលសមុទ្រតិចតួច។ លោកម៉ាក ប៊ុកប៊ី និយាយទៀតថា «វាអាចមានសារជាតិសូដ្យូមបន្តិចបន្តួច។ ប៉ុន្តែវាគឺជាទឹកសុទ្ធ និងស្រទន់បំផុត។ នៅក្នុងទឹកដែលមានប្រភពពីភ្នំ ជាធម្មតា គេរកឃើញនូវអត្រាដ៏ខ្ពស់នៃជាតិម៉ាញេស្យូម នីត្រាត ផូស្វ័រ និងប៉ូតាស្យូមធម្មជាតិ»។

ស្ថានីយត្រួតពិនិត្យនៅជ្រោយកាបហ្គ្រីម និងខ្យល់បរិសុទ្ធដែលគេបានវាស់ផ្តល់ឲ្យសហគ្រិននៅក្នុងតំបន់នូវសារៈប្រយោជន៍ប្រកួតប្រជែង ដែលវាមានតម្លៃខ្លាំង។«ហើយវាប្រហែលជាមិនអាចនឹងទៅរួចដែរ ប្រសិនបើគ្មានស្ថានីយវាស់ស្ទង់”។ មែន វាដូចជាគេលក់រឿងអណ្តែតអណ្តូង ប៉ុន្តែគេមានទិន្នន័យរយៈពេល ៤៣ឆ្នាំ ដែលបង្ហាញថា នៅតំបន់នេះមានការលាយនៃខ្យល់ដែលបរិសុទ្ធបំផុតនៃពិភពលោក»។

ទោះបីជាយ៉ាងណា វាក៏ជាតំបន់ដែលងាយទទួលរងនឹងការបំពុលដែរ។ លោកសំ គ្លីឡេន បញ្ជាក់ថា ទោះបីជាយ៉ាងណាក្តី ជ្រោយនេះមិនអាចគេចផុតទាំងស្រុងពីកម្រិតដែលចេះតែកើនឡើងនូវការបំពុល។ នៅពេលដែលខ្យល់មកពីភាគខាងជើង មកពីទីក្រុងមែលប៊ន ឬស៊ីដនី វាអាចទៅរួចនឹងត្រួតពិនិត្យឃើញអំពីដាននៃជាតិគីមីមកពីរោងចក្រផ្សេងៗគ្នា ដែលមានសកម្មភាពនាពេលសព្វថ្ងៃនេះនៅប្រទេសអូស្ត្រាលី។

ស្ថានីយអាចវាស់រកឃើញការកើនឡើងនៃឧស្ម័ន ដែលនេះធ្វើឲ្យទន់ខ្សោយដល់ស្រទាប់អូសូន។ ការកើនឡើងនៃឧស្ម័នដែលមានប្រភពមកពីកន្លែងឆ្ងាយៗ ដូចជាប្រទេសចិន ក៏មានផងដែរ។ សូម្បីតែខ្យល់បរិសុទ្ធដែលមានប្រភពមកពីទិសនិរតីក៏មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សផងដែរនាពេលសព្វថ្ងៃនេះ៕



*ជ្រោយកាបហ្គ្រីម ជាប់ជាតំបន់មានខ្យល់បរិសុទ្ធបំផុត។ រូបភាព៖ Getting Image*



*វាលស្មៅលាតសន្ធឹងដ៏ធំ និងទឹកឆ្លុះពណ៌ត្រីស្តាលសមុទ្រអូស្ត្រាលី។ Getting Image*

# មនុស្សចាស់នៅកម្ពុជាទទួលការគាំពារពីរាជរដ្ឋាភិបាល

ដោយ៖ ផល សុផានិត

**ក្នុងឆ្នាំ២០១៩នេះ ពិភពលោកកំពុងកើនឡើងនូវមនុស្សចាស់ កាលពីប៉ុន្មានពេលមុនមនុស្សដែលមានវ័យចាប់ពី ៦០ឆ្នាំឡើងទៅ មានត្រឹមតែ៨ភាគរយតែប៉ុណ្ណោះ តែក្នុងពេល៥០ឆ្នាំទៅមុខទៀត មនុស្សចាស់អាចនឹងកើនឡើងដល់ ២២ភាគរយ។**

បើតាមក្រសួងផែនការរបស់ប្រទេសកម្ពុជា មនុស្សដែលមានវ័យចាប់ពី៦០ឆ្នាំឡើងទៅ កំពុងកើនឡើងពី៤.៤ ភាគរយ ទៅ៦ភាគរយ ក្នុងឆ្នាំ២០១៤ នឹងមានការកើនឡើងជាបន្តបន្ទាប់ទៀត ហើយក្នុងឆ្នាំ២០២៥ ចំនួននេះនឹងកើនឡើងទ្វេដងទៀតក្នុងប្រទេសកម្ពុជា។ បញ្ហាសំខាន់ៗរបស់មនុស្សចាស់ ដែលកើតមានការរស់នៅម្នាក់ឯង សុខភាព ការថែទាំកូនចៅតូចៗ ឱកាសតិចតួចក្នុងការរកប្រាក់ចំណូល និងពិបាកក្នុងការធ្វើដំណើរជាដើម។

ជាកត្តាធម្មជាតិ បញ្ហាជាច្រើនដែលមនុស្សចាស់កំពុងតែប្រឈម ការចុះខ្សោយនៃរាងកាយ ស្មារតី អារម្មណ៍ និងការបាត់បង់ចំណូលប្រចាំថ្ងៃ កំពុងធ្វើឱ្យមនុស្សវ័យចំណាស់ក្លាយទៅជាជនរងគ្រោះ។ បច្ចុប្បន្ននេះបញ្ហារបស់មនុស្សចាស់ សូម្បីតែការរស់នៅជាមូលដ្ឋានរបស់គាត់ ដូចជា អាហារ ការស្នាក់នៅ ថ្នាំ ក៏មិនទាន់បានផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់នោះដែរ។បើក្រឡេកមើលទៅមួយជ្រុងទៀត ក៏នៅមានមនុស្សចាស់ជាច្រើនទៀត រស់នៅតែម្នាក់ឯងឯកោ។

នេះគឺជាប្រការគ្រោះថ្នាក់មួយដែលយើងទាំងអស់គ្នាគួរយកចិត្តទុកដាក់។ ជាការពិត យើងទាំងអស់គ្នាបច្ចុប្បន្ន ធ្លាប់ក្មេង តែមិនធ្លាប់ចាស់ ហើយមនុស្សយើងម្នាក់ៗក៏មិនអាចគេចផុតពីវ័យចាស់ជរាបាននោះទេ ដូច្នេះការគិតគូរពីពេលបច្ចុប្បន្ននេះ វាអាចជាឱកាសមួយដែលអាចឱ្យយើង ជៀសផុតពីហានិភ័យក្នុងពេលអនាគត។

ផ្អែកតាមគោលនយោបាយជាតិស្ដីពីមនុស្សចាស់ បានកំពុងតែចាត់បញ្ជូនក្រុមការងារឱ្យចុះតាមដានអំពីមនុស្សចាស់ ដែលទទួលបន្ទុកដោយក្រសួងសង្គមកិច្ច។

លោក ចេង ដារ៉ាវុធ ប្រធាននាយកដ្ឋានសុខុមាលភាពមនុស្សចាស់ បាននិយាយថា ទាក់ទងទៅនឹងបញ្ហាមនុស្សចាស់នេះ ក្រសួងកំពុងតែយកចិត្តទុកដាក់បំផុតពីបញ្ហាសុខភាពមនុស្សចាស់នេះ ដែលយើងមានសេចក្ដីព្រៀងគោលនយោបាយអំពីមនុស្សចាស់ ដែលបានផ្ញើរួចមកហើយក្នុងខែកញ្ញា ឆ្នាំ២០១៨ សម្រាប់មនុស្សចាស់គ្រប់គ្នា។

ប្រធាននាយកដ្ឋានរូបនេះ បន្តថា មនុស្សដែលយើងចាត់ទុកជាមនុស្សចាស់គឺមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ តាមសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិ ប៉ុន្តែយើងក៏បានរៀបចំចំណាត់ថ្នាក់ពួកគាត់ ថាតើមួយណាដែលងាយរងគ្រោះជាងគេ ដែលនឹងត្រូវទទួលបានសេវាសង្គមកិច្ច លើសេវាសុខុមាលភាពថែមទៀត។

មនុស្សចាស់ជាបុព្វការីជនដែលបង្កើតឱ្យមាននូវផលផានដ៏មានប្រយោជន៍ ព្រមទាំងផ្ដល់ឱ្យមនុស្សជំនាន់ក្រោយនៅចំណោះដឹង ចំណោះធ្វើ វប្បធម៌ និងបទពិសោធន៍ ទៅកាន់មនុស្សពីមួយជំនាន់ទៅមួយជំនាន់ទៀត។

រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននេះ បង្កើតសមាគមមនុស្សចាស់ គឺជាការលើកស្ទួយនៅសុខុមាលភាពរបស់ពួកគាត់ នឹងធ្វើឱ្យជីវិតចុងក្រោយរបស់ពួកគាត់កាន់តែប្រសើរឡើង។

អត្ថប្រយោជន៍ទាំងនោះរួមមាន ទទួលបានការគាំពារសុខភាពនៅតាមមន្ទីរពេទ្យសាធារណៈ របបអាហារបន្ទាប់បន្សំ ការជួយគ្នាទៅវិញទៅមករវាងមនុស្សចាស់ និងមនុស្សចាស់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ប៉ុន្តែមិនអចិន្ត្រៃ លុះត្រាតែនិវត្តជនទើបបានអចិន្ត្រៃ ដែលយើងហៅថា ប្រាក់និវត្តជាបន្ទុករបស់ក្រសួងសង្គមកិច្ច។

លោកតា សំ អូន រស់នៅក្នុងខេត្តកំពង់ឆ្នាំង បាននិយាយថា ការបង្កើតសមាគម គឺរួមចំណែកធ្វើឱ្យពួកគាត់រីកចម្រើន និងមានលុយមានកាក់ដូចគេដូចឯង។

លោកយាយ គង់ សុភី ដែលជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ និយាយថាការបង្កើតសមាគម គឺមានប្រយោជន៍ដូចជា យើងចាស់ម្ដងម្នាក់ជួយគ្នាទៅវិញទៅមកក្នុងពេលក្រីក្រលំបាក។

គោលនយោបាយជាតិស្ដីពីមនុស្សចាស់ បានយកចិត្តទុកដាក់លើមនុស្សចាស់ និងបានជ្រើសរើសយកថ្ងៃទី១ ខែតុលា ជារៀងរាល់ឆ្នាំដើម្បី ប្រារព្ធទិវាមនុស្សចាស់ រួមជាមួយស្ថាប័ន អាជ្ញាធរជាតិ និងអង្គការអន្តរជាតិនានា ព្រមទាំងដំណើរការនៃគណៈកម្មការជាតិដើម្បីមនុស្សចាស់។

បច្ចុប្បន្នក្រៅពីសមាគ កម្ពុជាក៏នៅមានសកម្មភាពមួយចំនួនទៀតផងដែរ ក្នុងការជួយដល់ទុរគតជន និងមនុស្សចាស់ ព្រមទាំងចាស់ជរាគ្មានទីពឹង ក្នុងនោះកាកបាតក្រហមកម្ពុជា ពីមួយឆ្នាំទៅមួយឆ្នាំ កាន់តែយកចិត្តទុកដាក់ ជួយដល់ទុរគតជន ជនចាស់ជរាគ្មានទីពឹង នៅតាមបណ្ដាខេត្តផ្សេងៗ តាមរយៈការទំនុកបម្រុង និងសកម្មភាពមនុស្សធម៌ផ្សេងៗជាដើម៕



បញ្ហាសំខាន់ៗរបស់មនុស្សចាស់ ដែលកើតមានការរស់នៅម្នាក់ឯង សុខភាព ការថែទាំកូនចៅតូចៗ ឱកាសតិចតួចក្នុងការរកប្រាក់ចំណូល។ រូបភាព៖ ស៊ីអេសស៊ី





# លោក សួន យឿន៖ «ជំនឿគឺជាសេចក្ដីក្លាហានសម្រាប់ខ្ញុំ»



លោកសួន យឿន ទទួលអគ្គសញ្ញាជ្រមុជទឹក។ រូបភាព៖ ស៊ីអេសស៊ី

**ទោះបីវ័យចាស់យ៉ាងណាក៏ដោយ ការកែប្រែចិត្តគំនិតគឺសំខាន់ណាស់សម្រាប់ព្រះជាម្ចាស់។ ព្រះអង្គស្រលាញ់មនុស្សគ្រប់រូបទាំងអស់ មិនលើកលែងសូម្បីតែ មនុស្សបាប។ លោកសួន យឿន ក្នុងវ័យជិត៨០ឆ្នាំទៅហើយ ទើបតែ ទទួលអគ្គសញ្ញាជ្រមុជទឹក ដែលក្រុមគ្រួសាររបស់លោកសុទ្ធសឹងជាគ្រីស្ដបរិស័ទ។ ប៉ុន្តែក្នុងជីវិតស្ងប់ស្ងាត់ លោកបានចំណាយពេលជាច្រើនដើម្បីអានគម្ពីរ និងអធិដ្ឋានជាមួយព្រះជាម្ចាស់អស់ជាច្រើនឆ្នាំ តែ មិនទាន់ទទួលពិធីជ្រមុជទឹកនោះទេ។ លោកបានសម្រេចចិត្តទទួលពិធីនេះ ក្នុងឆ្នាំ២០១៩នេះប៉ុណ្ណោះ។**

ដោយ៖ រឿន ស្រីម៉ាច

លោក សួន យឿនវ័យ៧៦ឆ្នាំមានកូនប្រុសស្រី៤នាក់ក្នុងក្រុមគ្រួសារជាគ្រីស្ដបរិស័ទ មានទីលំនៅក្នុងសង្កាត់បឹងទំពុន រាជធានីភ្នំពេញ។

ទោះមានវ័យចាស់បន្តិចក៏ដោយ តែលោកបានបង្ហាញជំនឿរបស់ខ្លួនថា៖«ខ្ញុំជឿ និងស្រលាញ់ព្រះជាម្ចាស់តាំងពីដើមរហូតមក បើទោះបីជា មិនទាន់ជាគ្រីស្ដបរិស័ទពេញលេញក៏ពិតមែនគឺខ្ញុំតែងផ្ញើជីវិតទាំងស្រុងទៅព្រះជាម្ចាស់ដើម្បីតម្រង់ជីវិត និងបំភ្លឺផ្លូវខ្ញុំកន្លងមកតាមរយៈអធិដ្ឋាន និងការផ្ញើទានជាមួយអ្នកដទៃ»។

តាមការឱ្យដឹងពីលោកយឿន គឺលោកបានទទួលរៀនអប់រំជំនឿតាំងពីឆ្នាំ១៩៩២នៅជំរំសាយធូ តែដោយសារតែរវល់ នឹងបំពេញកិច្ចការដើម្បីផ្គត់ផ្គង់ជីវភាព ព្រោះកាលនោះគ្រួសារលោកជួបការលំបាកជាខ្លាំងរួមនឹងការអាក់អន់ស្រពន់ចិត្តនឹងរឿងរ៉ាវមួយចំនួន នាំឱ្យប៉ះទង្គិចផ្លូវចិត្តផង ទើបធ្វើឱ្យលោកមិនបានបន្តការឈ្វេងយល់ជំនឿជាមួយប្រពន្ធកូនរហូតមក។

ក្នុងឆ្នាំ២០១៨លោកបានកែប្រែចិត្តគំនិតពីការជឿលើព្រះយេស៊ូគ្រីស្ដ ដោយមកបន្តរៀនអប់រំជំនឿរហូតបានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១៩នៅរាត្រីបុណ្យចម្លង នៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន។

លោកសួន យឿន បន្ថែមថា កន្លងមកទោះបីជាមានការជំរុញពីក្រុមគ្រួសារយ៉ាងណាក៏ដោយ ក៏លោកមិនព្រមទទួលអប់រំជំនឿ និងអគ្គសញ្ញាជ្រមុជទឹកដែរ ព្រោះគិតថា អគ្គសញ្ញាជ្រមុជទឹកគ្រាន់តែជាពិធីមួយដើម្បីបំពេញសិទ្ធិតែប៉ុណ្ណោះ។

លោកថា៖ «ហេតុនេះខ្ញុំមិនចង់បន្តការឈ្វេងយល់អ្វីទៀតអំពីព្រះយេស៊ូដើម្បីបានទទួលឡើយ ព្រោះវ័យក៏ចាស់។អ្វីដែលសំខាន់គឺខ្ញុំទៅព្រះវិហារមានទំនាក់ទំនងជាមួយព្រះយេស៊ូរាល់ថ្ងៃទៅបានហើយ។បើទោះបីជាគ្មានអ្នកណាដឹងតែ ព្រះជាម្ចាស់នឹងយល់អំពីជំនឿខ្ញុំចំពោះទ្រង់»។

លោកបន្តថា៖ «តែប្រហែលព្រះអង្គមិនចង់ឱ្យខ្ញុំនៅស្ងៀមបែបនេះ ទើបបណ្ដាលចិត្តខ្ញុំឱ្យហ៊ានបង្ហាញខ្លួនថាចង់ក្លាយជាគ្រីស្ដបរិស័ទពេញសិទ្ធិរហូតបានទទួលអគ្គសញ្ញាជ្រមុជទឹកបែបនេះ»។

លោក យឿន បន្ថែមទៀតថា អ្នកជិតខាង ឬអ្នកធ្លាប់ស្គាល់គ្នា តែងតែនិយាយមិនល្អ ឬសើចយំដោយសេចក្ដីមើលងាយ ដោយសារការចូលសាសនាកាតូលិកនេះ។ តែលោកមិនបានឆ្លើយតបទៅគេវិញទេ គឺលើកលែងទោសឱ្យពួកគេតាមរយៈការថ្វាយទៅព្រះជាម្ចាស់ ត្បិតលោកគិតថាគ្មានអ្នកណា វាស់ជម្រៅចិត្ត និងជំនឿរបស់ខ្លួនបានក្រៅតែពីព្រះជាម្ចាស់ម្នាក់គត់។ ហេតុនេះ ទោះសល់ដង្ហើមចុងក្រោយក៏លោកខំប្រឹងស្វែងរកព្រះអង្គដែរ។

សម្ដីមួយៗដោយទឹកមុខញញឹម លោក យឿន បន្តថា៖«កាលពីមុនខ្ញុំជាមនុស្សមិនសូវនិយាយច្រើន តែជាមនុស្សមានះ គឺខឹងគេ ដើរមិនមាត់ ហើយដើរចេញទាំងចិត្តគំនុំ។ តែពេលនេះខ្ញុំខិតខំកែប្រែពីចរិតលក្ខណៈមិនល្អមកជាមានចិត្តសុភាពរាបសារ ដាក់ចិត្តស្រលាញ់ និងថ្វាយខ្លួនទៅព្រះជាម្ចាស់អស់មួយជីវិត។ ទោះបីខ្ញុំមិនមានកម្លាំងទៅក្រៅដើម្បីប្រកាសដំណឹងល្អពិតមែន តែកិច្ចការមួយដែលខ្ញុំធ្វើរាល់ថ្ងៃនោះគឺការអធិដ្ឋាន»។



កខគឃង។ រូបភាព៖ ស៊ីអេសស៊ី

លោក យឿន បន្តថា គាត់ខិតខំទៅព្រះវិហាររាល់ថ្ងៃអាទិត្យ លើកលែងតែពេលគាត់ឈឺប៉ុណ្ណោះ។ ហើយគាត់សប្បាយចិត្តនៅពេលឃើញកូនចៅទៅវិហារ។ បុរសវ័យចំណាស់នេះបន្តថា៖ «មនុស្សចាស់ដូចខ្ញុំមិនដឹងថាមានពេលប៉ុន្មានដងទៀតបានអង្គុយស្ដាប់លោកទេសនា និងជួបជុំគ្រីស្ដបរិស័ទដូចថ្ងៃអាទិត្យ? ហេតុនេះ ការចូលរួមអភិបូជាថ្ងៃអាទិត្យ គឺជាកិច្ចការសំខាន់សំរាប់ខ្ញុំ»។

ក្ដីស្រម៉ៃរបស់លោក សួន យឿន គឺចង់ឱ្យព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាមានការរីកចម្រើនឡើងជាលំដាប់។ មានលោកបូជាចារ្យ និងដូនជីកាតូលិកខ្មែរជាច្រើន មនុស្សមើលមកគ្នាដោយក្រសែភ្នែកក្ដីស្រលាញ់ និងភាពអាណិតអាសូរគ្នាទៅវិញទៅមក។ ក្នុងព្រះវិហារមានមនុស្សមកថ្វាយអភិបូជាកាន់តែច្រើន ជាពិសេស ឪពុកម្ដាយបញ្ជូនបន្តជំនឿដល់កូនៗពីមួយជំនាន់ទៅមួយជំនាន់មិនឱ្យសាបសូន្យ៕

# សូមបងស្រីសម្រាកក្នុងសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ដ

*ដោយ៖ លី សុវណ្ណា*

បងស្រី ហ្ស៊ីលប៊ែរ ម៉ាស៊ុង GILBERTE MASSON ក្នុងក្រុមបងស្រីព្រះមាលា នៅប៉ុងឌឺបូវ័រសាំង Rosaire de Pont de Beauvoisin បានទទួលមរណភាពហើយ នៅថ្ងៃព្រហស្បតិ៍ ទី០៩ ខែឧសភា ឆ្នាំ ២០១៩ នៅ សំប៊ែរី ប្រទេសបារាំង។

បងស្រីហ្ស៊ីលប៊ែរប្រសូត នៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៣៧។ បងស្រីទទួលមរណភាពក្នុងជន្មាយុ ៨២ឆ្នាំ ដោយរោគាពាធ ក្នុងអារាមរបស់បងស្រី នៅប្រទេសបារាំង។

បងស្រីបានចាប់ផ្ដើមកិច្ចការការងាររបស់ខ្លួនជាមួយប្រជាជនកម្ពុជា នៅក្នុងជំរំជនភៀសខ្លួនតាមព្រំដែន កម្ពុជា-ថៃ ក្នុងនាមជាសាសនទូត។ នៅឆ្នាំ១៩៩២ បងស្រីបានបន្តបេសកកម្មនៅក្នុងប្រទេសកម្ពុជាជាមួយលោកឪពុកប៉ុងស៊ូដ៍ ដើម្បីរៀបចំសៀវភៅអប់រំជំនឿ និងសិក្ខាសាលានានា សម្រាប់គ្រូអប់រំជំនឿនៅទូទាំងប្រទេសកម្ពុជា។

បងស្រីធ្វើការងារយ៉ាងច្រើនសម្រាប់ព្រះសហគមន៍កាតូលិកនៅកម្ពុជា តាមរយៈការិយាល័យអប់រំជំនឿកាតូលិក។ សៀវភៅអប់រំជំនឿដែលព្រះសហគមន៍ប្រើសព្វថ្ងៃសម្រាប់កិច្ចការអប់រំជំនឿ គឺជាសមិទ្ធិផលដែលចេញពីការខិតខំប្រឹងប្រែងដ៏អស្ចារ្យរបស់បងស្រី។

***ការស្ម័គ្រចិត្តបម្រើ ការលះបង់ និងការបូជារបស់បងស្រី ពិតជាផ្ដល់នូវកិត្តិយសដល់យើងខ្ញុំ និងមានគុណបំណាច់យ៉ាងធំធេង***



*បងស្រី ហ្ស៊ីលប៊ែរ ម៉ាស៊ុង GILBERTE MASSON ក្នុងក្រុមបងស្រីព្រះមាលា នៅប៉ុងឌឺបូវ័រសាំង Rosaire de Pont de Beauvoisin។ រូបភាព៖ រ៉ាន់ សម្បត្តិ*

ចំណែកឯលោកគ្រូ ដួង សាវង់ ជាប្រធានការិយាល័យអប់រំជំនឿកាតូលិក ដែលជាអតីតសហការីម្នាក់របស់បងស្រី បានរៀបរាប់ថា បងស្រីមានគំរូជាច្រើនសម្រាប់រូបលោក គឺនៅក្នុងការងារ បងស្រីជាមនុស្សច្បាស់លាស់ហ្មត់ចត់ មានគោលដៅពិតប្រាកដ ការរៀបចំកិច្ចការអ្វីមួយសុទ្ធតែមានគំរោងការ។ បងស្រីមានការព្យាយាមអត់ធ្មត់ មានចិត្តធូន់ និងចិត្តស្រលាញ់យ៉ាងពិតប្រាកដ។ បងស្រីមានទស្សនវិស័យច្បាស់លាស់។

លោកបានបន្តទៀតថា៖ «ខ្ញុំចាំមិនភ្លេចទេ គឺបងស្រីជាអ្នកជំរុញឲ្យមានការបណ្ដុះបណ្ដាលសម្រាប់អ្នកបន្តវេណដោយជំរុញឲ្យមានការបញ្ជូនបងប្អូនឲ្យទទួលការអប់រំនៅក្រៅប្រទេសលើកិច្ចការអប់រំជំនឿ។ ជាលទ្ធផល គឺបេក្ខជនបីរូបពីកម្ពុជាទៅសិក្សានៅប្រទេសបារាំង។ បងស្រីក៏បានផ្ដល់ឲ្យមានការចូលរួមក្នុងសិក្ខាសាលអន្តរជាតិអំពីអប់រំជំនឿ នៅប្រទេសបារាំង ដែលបានបញ្ជាក់ថា ការអប់រំជំនឿនៅកម្ពុជា ដូចនៅប្រទេសបារាំងដែលគេកំពុងយកចិត្តទុកដាក់។ បងស្រីបានបង្កើតអ្វីថ្មីៗ សម្រាប់ការអប់រំជំនឿនៅកម្ពុជា»។

លោកបញ្ជាក់ថា៖ «បងស្រី បំពេញកិច្ចពោរពេញដោយសេចក្ដីស្រលាញ់ ការអត់ធ្មត់ជានិច្ច»។

លោកគ្រូ ដួង សាវង់ ក៏បានលោកឡើងដែរថា ៖«ក្រៅពីកិច្ចការអប់រំជំនឿ បងស្រីក៏បានបំពេញកិច្ចមនុស្សធម៌ក្នុងសង្គមផងដែរ គឺ ជួយអ្នកក្រីក្រ ឲ្យការងារ ឲ្យមានការសិក្សា សម្រាប់យុវជនយុវនារី ជាពិសេសយុវនារី ជួយគេឲ្យទទួលបានការសិក្សានៅថ្នាក់មធ្យមសិក្សា និងថ្នាក់ឧត្ដមសិក្សា។

អំពីគំរូនៃជំនឿលោកគ្រូ ដួង សាវង់ ក៏បានបញ្ជាក់ថា បងស្រី តែងរំលឹងកជានិច្ចអំពីជំនឿ ចែករំលែក ព្រះបន្ទូល ក្នុងពេលអធិដ្ឋាន ទៅអភិបូជាទៀងទាត់។ បងស្រីធ្លាប់លើកទឹកចិត្តថា ការចូលរួមអភិបូជា ការអធិដ្ឋានសំខាន់ណាស់ ពេលយើងធ្លាក់ជំនឿ ការជួបជុំបងប្អូននៅព្រះវិហារ គឺសំខាន់ណាស់ ដើម្បីលើកទឹកចិត្តយើង ក្នុងការបន្តដំណើរទៅមុខ។

លោក កាន់ ប៊ុយ ជាយុវជន ដែលទៅសិក្សានៅប្រទេសបារាំង ក្រោមការជំរុញគាំទ្ររបស់បងស្រី ហ្ស៊ីលប៊ែរ និងជាអ្នកបានជួបបងស្រីប៉ុន្មានសប្ដាហ៍មុនបងស្រីទទួលមរណភាព បាននិយាយលើហ្វេសប៊ុកផ្ទាល់ខ្លួន ដោយភ្ជាប់ជាមួយរូបភាពរបស់បងស្រីផងថា៖ ការស្ម័គ្រចិត្តបម្រើ ការលះបង់ និងការបូជារបស់បងស្រី ពិតជាផ្ដល់នូវកិត្តិយសដល់យើងខ្ញុំ និងមានគុណបំណាច់យ៉ាងធំធេងដែលមិនអាចបំភ្លេចបានឡើយ។ បងស្រី ឃ្លាតតែរូបកាយ តែវិញ្ញាណឋិតនៅជាមួយយើងខ្ញុំ។ នៅថ្ងៃនេះ យើងខ្ញុំរួមគ្នាប្រារព្ធចំពោះបងស្រី ដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ការលះបង់ដ៏មានតម្លៃរបស់បងស្រី។ យើងខ្ញុំនឹកគិតដល់បងស្រីដើម្បីបន្តកិច្ចការទាំងឡាយដោយយកចិត្តទុកដាក់ និងដោយស្មារតីទទួលខុសត្រូវដើម្បីទទួលផលនៃសេចក្ដីសុខសាន្ត និងអំណរសប្បាយនាពេលអនាគត។ យើងខ្ញុំនឹករំឭក និងនឹកចាំពីកម្លាំងកាយ កម្លាំងចិត្តដែលបងស្រីបានលះបង់ ដើម្បីឲ្យការនឿយហត់របស់បងស្រីមានតម្លៃ និងមានអត្ថន័យជានិច្ចចំពោះព្រះសហគមន៍នៅប្រទេសកម្ពុជា។

បងស្រីបានត្រឡប់ទៅរស់នៅក្នុងក្រុមព្រះមាលា ប៉ុងឌឺបូវ័រសាំង ប្រទេសបារាំងវិញ កាលពីពីរឆ្នាំមុន ដោយសារបញ្ហាសុខភាព។ បងស្រីបានលះបង់ចិត្តកាយប្រាជ្ញាសម្រាប់ព្រះសហគមន៍កាតូលិកនៅកម្ពុជា រយៈពេល២៨ឆ្នាំ និងជាង២៨ឆ្នាំសម្រាប់ប្រជាជនខ្មែរទូទៅ។

យើងសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ការខ្នះខ្នែង និងការបម្រើដោយអស់ពីចិត្តរបស់បងស្រី ចំពោះព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា ជាពិសេសបានជួយយ៉ាងច្រើនដល់អ្នកស្វែងយល់ឲ្យស្គាល់អំពីការរស់នៅរបស់ព្រះយេស៊ូ៕





# ១០ចំណុចសំខាន់ លោកអភិបាលព្រះសហគមន៍ រំលឹកដល់បូជាចារ្យនៅថ្ងៃរំលឹកពាក្យសច្ចា

*ដោយ៖ សួន ស្រីហ្វូចដាលីស*

លោកអូលីវិយេ អភិបាលព្រះសហគម៍កាតូលិក បានលើកឡើង ១០ចំណុចសំខាន់ៗដើម្បីរំលឹកដល់អស់លោកបូជាចារ្យទាំងអស់ នៅក្នុងប្រទេសកម្ពុជា ក្នុងពិធីអភិបូជាប្រសិទ្ធពរលើប្រេង ដែលបានធ្វើឡើងនាល្ងាចថ្ងៃទី៩ ខែមេសា ឆ្នាំ ២០១៩ នៅព្រះវិហារសន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី។ អភិបូជាប្រសិទ្ធពរលើប្រេង ជាពិធីយ៉ាងឱឡារិកដើម្បីបង្ហាញភាពជាផ្លុងមួយរបស់លោកបូជាចារ្យ និងលោកអភិបាលព្រះសហគមន៍។



*លោកអភិបាល អូលីវិយេ អភិបាលព្រះសហគម៍កាតូលិក និងលោកបូជាចារ្យទាំងអស់នៅក្នុងប្រទេសកម្ពុជា ក្នុងពិធីអភិបូជាប្រសិទ្ធពរលើប្រេង។ រូបភាព៖ ស៊ីអេសស៊ី*

ពិធីនេះក៏ជាពេលដែលអស់លោកបូជាចារ្យ ត្រូវប្រកាសពាក្យសច្ចារបស់ខ្លួនឡើងវិញនៅចំពោះមុខលោកអភិបាល និងព្រះសហគមន៍ទាំងមូល។

នៅក្នុងធម្មទេសនារបស់លោកអភិបាលអូលីវិយេ មានប្រសាសន៍ទៅកាន់អស់លោកបូជាចារ្យ ដែលជាគង្វាលព្រះសហគមន៍នូវចំណុចសំខាន់ៗដូចជា៖

ទីមួយ៖ សូមយកចិត្តទុកដាក់ថែរក្សាជីវិតខាងផ្លូវវិញ្ញាណ។

ទីពីរ៖ ការពារថែរក្សាអង្គតែមួយ គឺសំខាន់ណាស់ ដោយមើលគំរូព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីស្រឡាញ់គ្នាជាផ្លុងតែមួយ នៅក្នុងព្រះសហគមន៍។

ទីបី៖ ធ្វើបរិយាបន្ន គឺធ្វើយ៉ាងម៉េចដើម្បីឲ្យមនុស្សទាំងអស់ចូលរួមជាមួយគ្នាបានដូចនៅក្នុងគ្រួសារតែមួយ។

ទីបួន៖ លើកលែងទោសដើម្បីចូលឲ្យជ្រៅនៅក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះបិតា។ ទីប្រាំ៖ ឲ្យយើងមានបេះដូងមួយដែលចេះស្ដាប់ ដែលចេះស្រឡាញ់នៅក្នុងសេចក្ដីពិត។

ទីប្រាំមួយ៖ សន្ទនា( Dialogue ) មិនត្រឹមតែការសន្ទនារវាងគ្នានិងគ្នា ប៉ុន្តែការសន្ទនាជាមួយសាសនាដទៃទៀត ការសន្ទនាជាមួយអាជ្ញាធរដែនដី ការសន្ទនានៅក្នុងសង្គមរបស់យើង គឺជាការសំខាន់ណាស់។

ទីប្រាំពីរ៖ ឲ្យយើងយកចិត្តទុកដាក់រស់នៅក្នុងសង្គមបច្ចុប្បន្ននេះ មិនមែនរស់នៅក្នុងសុបិន។ ទីប្រាំបី៖ ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីបន្តអប់រំ និងមិនមែនត្រឹមតែអប់រំជំនឿតែប៉ុណ្ណឹងទេ គឺអប់រំមនុស្សទាំងស្រុងទៀតផង។ ទីប្រាំបួន៖ ឲ្យយើងមានចិត្តដូចឪពុក និងម្ដាយ។ ព្រះសហគមន៍ជាគ្រួសារមួយ កុំឲ្យយើងភ្លេចថាព្រះសហគមន៍ជាដើមឈើមួយដ៏ធំបំផុត ដែលមានបេះដូងដ៏ធំធេងដោយចេះស្វាគមន៍គ្រប់បក្សាបក្សី ដែលចង់បង្កើតសង្គមមួយ។

និងទីដប់៖ ឲ្យចេះច្នៃប្រតិដ្ឋ កុំគិតថាដំណឹងល្អយើងធ្លាប់ស្ដាប់ ទេសនាដដែលៗ ប៉ុន្តែថ្ងៃនេះព្រះបន្ទូលមានអត្ថន័យថ្មី ដោយធ្វើយ៉ាងម៉េចដើម្បីមើលឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅក្នុងសញ្ញាដ៏តូចតាចនៃជីវិត។

លោកបូជាចារ្យកាតូលិកទាំងអស់ត្រូវប្រកាសពាក្យសច្ចាឡើងវិញជារៀងរាល់នៅថ្ងៃបុណ្យប្រសិទ្ធីពរលើប្រេង នៅចំពោះមុខលោកអភិបាល និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដោយចង់រួមរស់ រួមស្លាប់ជាមួយព្រះយេស៊ូគ្រីស្ដ អស់ពីចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រកាន់យ៉ាងស្មោះត្រង់តាមពាក្យសន្យា ហើយបំពេញបេសកកម្មរបស់ខ្លួនក្នុងព្រះសហគមន៍ និងធ្វើជាគង្វាលដ៏ប្រពៃ។

ពិធីអភិបូជាប្រសិទ្ធីពរលើ ប្រេង គឺប្រារព្ធធ្វើជារៀងរាល់ថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៅចុងរដូវអប់រំពិសេស មុនថ្ងៃបុណ្យព្រះយេស៊ូរងទុក្ខលំបាក។ ប្រេងដែលប្រសិទ្ធិរួចហើយ គឺយកទៅប្រើប្រាស់ក្នុងពិធីផ្សេងៗរបស់ព្រះសហគន៍ពេញមួយឆ្នាំ។

ប្រេងដែលប្រសិទ្ធីពរនោះមានបីយ៉ាង គឺ៖ ១) ប្រេងសម្រាប់លាបដើម្បីផ្ដល់កម្លាំងឲ្យអ្នកជម្ងឺ ចាស់ជរាជនពិការ និងអស់អ្នកដែលរងទុក្ខលំបាក។ ២) ប្រេងសម្រាប់អ្នករៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក និងអស់អ្នកដែលមិនទាន់ស្គាល់ព្រះយេស៊ូ។ ៣) ប្រេងគ្រីស្មា ដែលប្រើសម្រាប់អគ្គសញ្ញាលាបថ្ងាស សម្រាប់អស់អ្នកដែលស្ម័គ្រចិត្តថ្វាយខ្លួនជាអ្នកបម្រើព្រះជាម្ចាស់ សម្រាប់និស្សិតទេវវិទ្យាល័យ អគ្គសញ្ញាតែងតាំងជាបូជាចារ្យជាអភិបាល និងសម្រាប់ទីសក្ការៈនានានៃព្រះសហគមន៍ទាំងអស់ដើម្បីធ្វើជាសាក្សីនៃព្រះយេស៊ូ។

លោកបានបញ្ជាក់ថា មានតែលោកអភិបាលទេដែលមានសិទ្ធិប្រសិទ្ធិពរប្រេងទាំងនោះបាន ដោយសូមព្រះជាម្ចាស់គង់នៅជាមួយព្រះសហគមន៍ ដែលជាមូលហេតុមានបងប្អូនមកពីតំណាងព្រះសហគមន៍ទាំងអស់៕



## មូលហេតុអ្វី ព្រះសហគមន៍កាតូលិក គូសសញ្ញាឈើឆ្កាងជាសម្គាល់? មានន័យដូចម្ដេច?

*ដោយ៖ លោកបូជាចារ្យរឿង ឆ័ត្រសិរី*

ជីវិតគ្រីស្ដបរិស័ទ យើងថ្វាយខ្លួនទៅព្រះត្រៃឯក។ យើងប្រើសញ្ញា ដោយមានគូសឈើឆ្កាង នៅលើខ្លួនរបស់យើង និងប្រើពាក្យ «ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ» មានន័យថា យើងអញ្ជើញព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើយើង ជាពិសេសនៅពេលយើងធ្វើសកម្មភាពណាមួយ ដើម្បីឲ្យសកម្មភាពរបស់យើងក្លាយជាសកម្មភាពរបស់ព្រះជាម្ចាស់។

នេះជួយឲ្យយើងមានស្មារតីថា កម្មវិធីដែលយើងកំពុងធ្វើនេះ ជាកម្មវិធីរបស់ព្រះជាម្ចាស់ដែរ ជាពិសេសនៅពេលយើងចូលព្រះវិហារ អធិដ្ឋានឬអ្វី យើងតែងតែអញ្ជើញព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធយាងមក៕



ព្រះសហគមន៍មណ្ឌលសកម្មភាពកំពត បានប្រារព្ធបុណ្យនេះ នៅព្រះវិហារលើភ្នំបូកគោ ដែលជាព្រះវិហារដ៏ចំណាស់មួយដែលនៅសេសសល់ពីការបំផ្លាញរបស់ប៉ុលពត។ ។
រូបភាព៖ ង៉ែត សុធីរិទ្ធ

# លោកអភិបាល ជំរុញគ្រីស្តបរិស័ទប្រកាសដំណឹងល្អឱ្យព្រះបន្ទូលកើតជារូបរាង

*ដោយ៖ លី សុវណ្ណា*

«ប្រកាសដំណឹងល្អដើម្បីឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូកើតជារូបរាង នៅពេលនេះ នៅទីនេះ នៅក្នុងព្រះសហគមន៍យើង នៅក្នុងប្រទេសកម្ពុជាយើង នៅក្នុងគ្រួសារយើង»។ នេះជាប្រសាសន៍របស់លោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ ក្នុងធម្មទេសនាកាលពីថ្ងៃបុណ្យគោរពព្រះយេស៊ូសោយទិវង្គត នាព្រឹក ថ្ងៃទី ១៩ ខែមេសា កន្លងទៅ។

ព្រះសហគមន៍មណ្ឌលសកម្មភាពកំពត បានប្រារព្ធបុណ្យនេះ នៅព្រះវិហារលើភ្នំបូកគោ ដែលជាព្រះវិហារដ៏ចំណាស់មួយដែលនៅសេសសល់ពីការបំផ្លាញរបស់ប៉ុលពត។ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងបរិស្ថាន បានប្រគល់ជូនព្រះសហគមន៍កាតូលិក គ្រប់គ្រងថែរក្សា កាលពីចុងឆ្នាំ ២០១៧។

មានគ្រីស្តបរិស័ទជាច្រើនបានចូលរួមពិធីបុណ្យ នេះដោយបានអធិដ្ឋានតាមដំណាក់នីមួយៗនៃទុក្ខលំបាករបស់ព្រះយេស៊ូមុនពេលគេយកព្រះអង្គទៅឆ្កាង និងក្នុងពេលសោយទិវង្គនៅលើឈើឆ្កាង។

លោកអភិបាលក៏បានលើកឡើងដែរថា ព្រះយេស៊ូសោយព្រះទិវង្គតហើយ សូមយើងនៅស្ងៀមស្ងាត់ ដោយអធិដ្ឋាននៅក្នុងដួងចិត្ត ដោយទទួលព្រះបន្ទូលដែលយើងបានស្តាប់អំបាញ់មិញ។ ពីយប់មិញយើងបានអង្គុយរួមតុជាមួយព្រះយេស៊ូ ដែលជប់លៀងជាមួយក្រុមសាវ័ក និងជាមួយយើងដែរ។ នៅពេលនេះ យើងនៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូដែលសោយទិវង្គត។ពីយប់មិញ យើងបានស្តាប់ព្រះយេស៊ូមានព្រះបន្ទូលថា នេះជាព្រះកាយ នេះជាព្រះលោហិតរបស់ខ្ញុំ។ នៅថ្ងៃនេះយើងមើលជាក់ស្តែង ព្រះកាយរបស់ព្រះគ្រីស្ត នៅលើឈើឆ្កាង។ព្រះលោហិតរបស់ព្រះគ្រីស្តហូរចេញពីត្រង់ឆ្អឹងជំនីរបស់ព្រះអង្គ។ ព្រះយេស៊ូបានសោយទិវង្គត នៅក្នុងអត្ថន័យថា ព្រះយេស៊ូបានបូជាជីវិត ដើម្បីឲ្យយើងទទួលជីវិតនេះ ដើម្បីឲ្យយើងទទួលពន្លឺនៅក្នុងដួងចិត្តរបស់យើង។

លោកបន្តថា៖ «ព្រះយេស៊ូជាសេចក្តីពិត ដោយសារព្រះយេស៊ូពោរពេញដោយភាពដ៏វិសុទ្ធ ដ៏ពេញលក្ខណៈ។ព្រះយេស៊ូជាព្រះអម្ចាស់ដ៏សុចរិតដ៏ពេញលក្ខណៈ។ នៅពេលនេះរួមជាមួយប្រជាជនយើងនឹកឃើញ គ្រប់ស្នាព្រះហស្តរបស់ព្រះអង្គ មានព្យាបាលអ្នកជំងឺ ណែនាំអ្នកអស់សង្ឃឹមរកឃើញពន្លឺនៅក្នុងជីវិត ណែនាំឲ្យមនុស្សពិការដើរបាន មនុស្សថ្លង់ស្តាប់ឮ មនុស្សខ្វះមើលឃើញ។ ណែនាំមនុស្សបាបមានជីវិតថ្មី ណែនាំមនុស្សដែលវង្វេងនៅក្នុងផ្លូវនៃជីវិតរកឃើញផ្លូវដើរបាន នៅក្នុងពន្លឺ និងក្នុងសេចក្តីពិត។ព្រះយេស៊ូបានណែនាំឲ្យមនុស្សយ៉ាងច្រើន បានទទួលសេចក្តីសង្ឃឹមសារជាថ្មី។ ថ្ងៃនេះគេឆ្កាងព្រះយេស៊ូ យើងដឹងថាទុក្ខលំបាករបស់យើងផ្ទាល់ ទុក្ខលំបាករបស់មនុស្សលោក ទុក្ខលំបាករបស់ព្រះសហគមន៍ យើងអាចផ្ញើទៅលើព្រះយេស៊ូ។

លោកបានរំលឹកគ្រីស្តបរិស័ទឲ្យរិះគិត គ្រប់ពេលវេលាហ្នឹង យើងស្តាប់ម្តងទៀតព្រះយេស៊ូ ដែលមានព្រះបន្ទូលថា «ខ្ញុំស្រេកទឹក!" តើយើងជាអ្នកដែលឲ្យទឹកទៅព្រះយេស៊ូ? តើយើងជាអ្នកណែនាំឲ្យមនុស្សតូចតាច រកឃើញផ្លូវនៅក្នុងជីវិតពោរពេញដោយសេចក្តីសង្ឃឹម? កុមារកំព្រា កូនក្មេងដែលគ្មានទីពឹង គ្រួសារដែលគ្មានសេចក្តីសុខ គ្រួសារដែលបាក់បែកគ្នា តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យមនុស្សទាំងអស់ ចូលទៅរស់នៅក្នុងគ្រួសាររបស់ព្រះគ្រីស្ត ដែលរកឃើញសេចក្តីសង្ឃឹមនៅក្នុងជីវិត? ជាពិសេសកូនក្មេង ដែលជួនកាលធ្វើការជាទាសករ ជាឧបករណ៍។ កូនក្មេងដែលបាត់ភាពដ៏វិសុទ្ធដោយសារមនុស្សពេញវ័យវង្វេងផ្លូវ និងស្មារតី។ កូនក្មេងដែលបាត់បង់ជីវិតដោយសារសង្គ្រាម កូនក្មេងដែលកើតហើយគ្មានវាសនា ទៅសាលារៀនដូចគេ មានមន្ទីរពេទ្យដូចគេ មានផ្ទះស្នាក់នៅដូចគេ មានឪពុកម្តាយដែលស្រលាញ់ដូចគេ។ យើងថ្វាយទៅព្រះជាម្ចាស់។

ព្រះសហគមន៍យកចិត្តទុកដាក់បំផុត បន្តកិច្ចការរបស់ព្រះយេស៊ូ ក្នុងលោកនេះ ដើម្បីឲ្យមនុស្សទាំងអស់ទទួលសេចក្តីសង្ឃឹម និងពន្លឺថ្មី ពីជីវិតថ្មី៕





គ្រីស្តបរិស័ទជាច្រើនបានចូលរួមពិធីបុណ្យ នេះដោយបានអធិដ្ឋានតាមដំណាក់នីមួយៗនៃទុក្ខលំបាករបស់ព្រះយេស៊ូ។ រូបភាព៖ ង៉ែត សុធីរិទ្ធ





# ការផ្លាស់ប្តូរទីកន្លែងលោកបូជាចារ្យព្រះសហគមន៍ភូមិភាគភ្នំពេញ

*ដោយ៖ លី សុវណ្ណា*

លោកអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ បានចេញលិខិតផ្លាស់ប្តូរ លោកបូជាចារ្យជំនួយ តាមមណ្ឌលសកម្មភាពព្រះសហគមន៍ នៃភូមិភាគភ្នំពេញ។

តាមលិខិតចុះថ្ងៃទី១០ ខែឧសភា បានបញ្ជាក់ថា លោកបូជាចារ្យដែលត្រូវផ្លាស់ប្តូរទីកន្លែង និងចាត់តាំងថ្មីមានដូចជា៖ សម្រាប់ព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើង ដែលលោក រឿងឆ័ត្រ ស៊ីរី បូជាចារ្យទទួលខុសត្រូវ។ លោក ដាវីឌ ជ័រ ណាស់ ជាបូជាចារ្យជំនួយ និងលោក ចន ពេង ជាបូជាចារ្យជំនួយ ដែលពេលមុនលោកជាបូជាចារ្យជំនួយនៅមណ្ឌលសកម្មភាពកំពត។

មណ្ឌលសកម្មភាពភ្នំពេញថ្មី ដែលមានលោក សួន ហង្សលី ជាបូជាចារ្យទទួលខុសត្រូវ។ លោក អារុកកៃដុស ជាបូជាចារ្យជំនួយ ដែលពេលមុនលោកជាបូជាចារ្យជំនួយនៅមណ្ឌលសកម្មភាពមេគង្គ។ ព្រះសហគមន៍ត្រែងត្រយឹង ដែលពេលមុនស្ថិតក្នុងមណ្ឌលសកម្មភាពកំពង់សោម ត្រូវកាត់ចូលមកមណ្ឌលសកម្មភាពភ្នំពេញថ្មី។

ចំណែកលោកឆាល កាលី ដែលពេលមុនជាបូជាចារ្យជំនួយនៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង ត្រូវប្តូរជាបូជាចារ្យជំនួយ ក្នុងមណ្ឌលសកម្មភាពកំពត ដែលមានលោក យ៉ាំងលូកា ជាបូជាចារ្យទទួលខុសត្រូវ។

លោក យុន អាប្រាហាំ ដែលពេលមុនជាបូជាចារ្យជំនួយនៅមណ្ឌលសកម្មភាពកំពង់សោម ត្រូវប្តូរមកបម្រើនៅមណ្ឌលសកម្មភាព មេគង្គ។

ការផ្លាស់ប្តូរនេះចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១ ខែកក្កដាឆ្នាំ២០១៩នេះតទៅ។

ក្នុងលិខិតនេះដែរលោកអភិបាលអូលីវីយេ ក៏បានបញ្ជាក់ដែរថាចាប់ពីថ្ងៃទី១០ ខែមិថុនាឆ្នាំ ២០១៩ លោកបូជាចារ្យ ហ្គូស្តាវ៉ូ ដែលកំពុងបម្រើនៅព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើង នឹងទៅបន្តការសិក្សារយៈពេលបីឆ្នាំនៅប្រទេសអ៊ីតាលី។ រយៈពេល១០ឆ្នាំ លោក ឪពុក ហ្គូស្តាវ៉ូ បានចូលរួម ជាច្រើន ដូចជា សកម្មភាពយុវជនភូមិភាគភ្នំពេញ ក៏ដូចជាយុវជនទូទាំងប្រទេសកម្ពុជា យុវជន FABC PMS ... ជាដើម។

ចំណែកលោក សាន់ដេ ហាតាឆៃ ក៏បានចាកចេញពីកម្ពុជាតាំងពីខែ មករា ឆ្នាំ២០១៩ និងកំពុងបន្តការសិក្សា៕



លោក ចន ពេង បូជាចារ្យជំនួយនៅព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើង។



លោក យុន អាប្រាហាំ ត្រូវប្តូរមកបម្រើនៅមណ្ឌលសកម្មភាព មេគង្គ



លោកបូជាចារ្យ ហ្គូស្តាវ៉ូ ទៅបន្តការសិក្សានៅប្រទេសអ៊ីតាលី រយៈពេលបីឆ្នាំ។



លោក ដាវីឌ ជ័រណាស់ បូជាចារ្យជំនួយ នៅព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើង។



លោក អារុកកៃដុស ជាបូជាចារ្យជំនួយក្នុងមណ្ឌលសកម្មភាពភ្នំពេញថ្មី។



លោក ឆាល កាលី ត្រូវប្តូរជាបូជាចារ្យជំនួយក្នុងមណ្ឌលសកម្មភាពកំពត



## អគ្គសញ្ញាលាបថ្ងាស
### នៅព្រះសហគមន៍កាតូលិកសន្តសិលានិង សន្តប៉ូល ភ្នំពេញថ្មី
### ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩។

ជីវិតគ្រីស្តបរិស័ទ យើងថ្វាយខ្លួនទៅព្រះត្រៃឯក។ យើងប្រើសញ្ញា ដោយមានគូសឈើឆ្កាង នៅលើខ្លួនរបស់យើង និងប្រើពាក្យ «ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ» មានន័យថាយើងអញ្ជើញព្រះមកសណ្ឋិតលើយើង ជាពិសេសនៅពេលយើងធ្វើសកម្មភាពណាមួយ ដើម្បីឲ្យសកម្មភាពរបស់យើងក្លាយជាសកម្មភាពរបស់ព្រះជាម្ចាស់។

នេះជួយឲ្យយើងមានស្មារតីថា កម្មវិធីដែលយើងកំពុងធ្វើនេះជាកម្មវិធីរបស់ព្រះជាម្ចាស់ដែរ ជាពិសេសនៅពេលយើងចូលព្រះវិហារ អធិដ្ឋាន ឬអី យើងតែងតែអញ្ជើញព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធយាងមក៕

# រូបភាពសកម្មភាពស្ដីអំពី ព្រះសហគមន៍ក្នុងខែឧសភា










Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវេរីតាស់អាស៊ីខេមរភាសា

សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយវិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហានុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្ដាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com និង www.catholiccambodia.org
- លោកអ្នក ក៏អាច Follow facebook ផ្លូការរបស់យើងតាមរយៈ www.facebook.com/RVAKHMER/

**តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវេរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុង (Khmer Live Audio)។

Radio Veritas Asia

Khmer Live audio

ឬ តាមរយៈគេហទំព័រ៖ http://rvakhmer.com